# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៣-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៦៤ ស្តីពីការតែងតាំងឯកឧត្តម **ឌុយ រី** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ២៨៩៩

២៥-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៦៥ ស្តីពី :

១-ត្រូវបានបញ្ឈប់ភារកិច្ចឯកឧត្តម **ហុង ស៊ុនហួត** ពីប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងឯកឧត្តម **នុត សុខុម** ពីអនុប្រធានប្រចាំការអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍។

២-ត្រូវបានកែសំរួលតម្លើងឋានៈ និងតែងតាំងសមាសភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍បន្ថែម ចំនួន ៤ រូប ២៩០០

២៥-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៦៦ ស្តីពី :

១-ត្រូវបានបញ្ឈប់ភារកិច្ចឯកឧត្តម **ឃី តាំងលឹម** ពីប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

២-ត្រូវបានកែសំរួលនិងតែងតាំងសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ចំនួន ៤ រូប ២៩០១

២៧-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៦៧ ស្តីពី ការតែងតាំង លោក **ឌី ម៉ូ** ជាឧកញ៉ា ២៩០២


## II-ក្រុមប្រឹក្សាធម្មនុញ្ញ


២៥-៨-២០០៣ -សេចក្តីសំរេចលេខ ០៥៥/០០៦/២០០៣ កបធ.ច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣ ២៩០៣

២៦-៨-២០០៣ -សេចក្តីសំរេចលេខ ០៥៦/០០៧/២០០៣ កបធ.ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៣ ២៩០៧

២៧-៨-២០០៣ -សេចក្តីសំរេចលេខ ០៥៧/០០៨/២០០៣ កបធ.ច ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣ ២៩១១


## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៦-៨-២០០៣ -អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៩២០

២៨-៨-២០០៣ -អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្តីពីក្រមសីលធម៌គ្រូពេទ្យ ២៩២២

២៥-៨-២០០៣ -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពីការលុបប្រកាសផ្ទេរ និង តែងតាំងមន្ត្រីរាជការ ២៩៤៣

២៦-៨-២០០៣ -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៩៤៤

២៦-៨-២០០៣ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៩៤៥

២៦-៨-២០០៣ -អនុក្រឹត្យលេខ ៧៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៤៨

32

# ខ


| | | |
|---|---|---|
| ២៧-៨-២០០៣ | -អនុក្រឹត្យលេខ ៧៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៥០ |
| ២៧-៨-២០០៣ | -អនុក្រឹត្យលេខ ៧៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៥១ |
| ២៧-៨-២០០៣ | -អនុក្រឹត្យលេខ ៧៥៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៩៥២ |
| ២៨-៨-២០០៣ | -អនុក្រឹត្យលេខ ៧៦០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូពាមជាំង | ២៩៥៣ |
| ២៩-៨-២០០៣ | -អនុក្រឹត្យលេខ ៧៦១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២៩៥៤ |
| ២៩-៨-២០០៣ | -អនុក្រឹត្យលេខ ៧៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៩៥៥ |
| ២៩-៨-២០០៣ | -អនុក្រឹត្យលេខ ៧៦៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២៩៥៦ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ២៨-៨-២០០៣ | -សេចក្តីសំរេចលេខ ៦២ សសរ ស្តីពីការបង្កើតគណៈកម្មការដេញថ្លៃគំរោងផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពត ទៅត្រពាំងរពៅ | ២៩៥៨ |


## IV-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ២៧-៨-២០០៣ | -ប្រកាសលេខ ៦០៦ សហវ ៧ដ ស្តីពីការបំពេញបន្ថែមការណែនាំអនុវត្តប្រមូលពន្ធប្រថាប់ត្រា | ២៩៥៩ |

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៦៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **នុយ រី** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣៧ល-០៣.០៤-២៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៣

លេខៈ ២១៤៤ ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវី តាន់

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨០៣/២៦៥

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១២៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការតែងតាំងនិងតំកល់ទុកអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ឈប់ភារកិច្ច ឯកឧត្តម ហុង ស៊ុនហួត ពីប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងឯកឧត្តម នុត សុខុម ពីអនុប្រធានប្រចាំការអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ។

**មាត្រា ២:** ត្រូវបានកែសំរួលតម្លើងឋានៈ និងតែងតាំងសមាសភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍បន្ថែម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ជាប្រធាន | |
| ២- ឯកឧត្តម លី ម៉ូរ | ជាអនុប្រធានប្រចាំការ | មានឋានៈស្មើរដ្ឋលេខាធិការ | |
| ៣- ឯកឧត្តម ហេង តៃគ្រី | ជាអនុប្រធាន | មានឋានៈស្មើរដ្ឋលេខាធិការ | |
| ៤- ឯកឧត្តម អ៊ឹង ឧុទ្ធី | ជាអនុប្រធាន | មានឋានៈស្មើរដ្ឋលេខាធិការ ។ | |

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ** លេខ: ២១៦៤ ល

៣រល.០៣.០៨.២៧៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ៗ ឆ្នាំ២០០៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាខី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៦៦

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០៨ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ឈប់ភារកិច្ច ឯកឧត្តម ឃី តាំងលឹម ពីប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

**មាត្រា ២:** ត្រូវបានកែសំរួល និងតែងតាំងសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និឧតុនិយម | ជាប្រធាន |
| ២- ឯកឧត្តម **ម៉ុក ម៉ារ៉េត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ជាអនុប្រធាន |
| ៣- ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ជាអនុប្រធាន |
| ៤- ឯកឧត្តម **ស៊ិន នីនី** | មានឋានៈស្មើរដ្ឋលេខាធិការ | ជាអនុប្រធាន ។ |

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ:២១៧ច ល

ពរល.០៣.០៥.៦៧៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ សីហា ឆ្នាំ ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង ឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

តែងតាំង

លោក ឌី ប៉ូ

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រស.០៣.០៨.២៧៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣

លេខៈ ៦១៩ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ០៧ ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាវ៉ ឡាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧០ /០១៤ / ២០០៣

ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ : ០៥៥ /០០៦ / ២០០៣ កបធ.ច

ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះសារលិខិតរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៨២ ហសប/ជស ចុះថ្ងៃទី ៦ ខែសីហាឆ្នាំ២០០៣ ផ្ទេរសិទ្ធិថ្វាយស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច ដើម្បីជាតំណាងក្នុងរឿងប្តឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បណ្តឹងលេខ ៦៥៧ ហសប/សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៣
- បានឃើញពាក្យបណ្តឹងរបស់ស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៥៧ ហសប.សរ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០៣ ប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និងគ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

ទទួលបាននៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១១:៣០នាទី

-បានឃើញលិខិតរបស់គណបក្សហ៊្វុនស៊ិនប៉ិចលេខ ៦៦៧ ហសប.សណ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៣ ឧទ្ទេសនាមលោក **ស៊ុន អរុណ** ជាប្រធានការិយាល័យមេធាវី និង លោក **ម៉ី ចំន្ទទាសនា** ជាប្រធានផ្នែករដ្ឋបាលមេធាវីរបស់គណបក្ស ដើម្បីបំពេញភារកិច្ចដាក់ពាក្យបណ្តឹង និង ទំនាក់ទំនងជាមួយក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញកំណត់ហេតុសួរយកចម្លើយ ដែលបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិច កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ពីតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣

-បានឃើញលិខិតពឹងពាក់មេធាវី លេខ ៦៧៨ ហសប.សណ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច សុំឱ្យមេធាវី ៦រូប ដើម្បីជាតំណាងក្នុងពេលសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ០៨.១៦៨៦/០៣ គ.ជ.ប ចុះថ្ងៃទី ២០ខែ សីហា ឆ្នាំ២០០៣ របស់ឯកឧត្តម **អ៊ឹម សូស្ដី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់តាំងតំណាង គ ជ ប ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និង លិខិតលេខ ០៨. ១៦៩០/០៣/គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០៣ របស់ឯកឧត្តម **អ៊ឹម សូស្ដី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបន្ថែមសមាជិក គ ជ ប ចំនួន ៣រូប ដើម្បីចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច បានដាក់បណ្តឹងលេខ ៦៥៧ ហសប.សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៣ មកក្រុមប្រឹក្សាធម្មនុញ្ញ ។ ដោយផ្អែកតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា បណ្តឹងនេះបានដាក់ក្នុងរយៈពេល ៧២ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា គណបក្សហ៊្វុនស៊ិនប៉ិច សុំប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលគេយល់ថា បានបំពេញភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និង គ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ ។ ពាក្យបណ្តឹងនេះសុំឱ្យផ្តន្ទាទោសគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមច្បាប់ជាធរមាន
- យល់ឃើញថា ពីដំបូងលោក **ស៊ុន អរុណ** បានឆ្លើយថា លោកមិនមែនជាតំណាងដើមបណ្តឹងទេ លោកជាមេធាវីតំណាងដើមចោទជាមួយនឹងមេធាវី ៥នាក់ទៀត ។ ក្រោយពីឯកឧត្តមប្រធានសួរបញ្ជាក់ថា តើមាន

ដើមបណ្ដឹងមកទេ ពេលនោះលោក **សុន អរុណ** ឆ្លើយថាគាត់ជាមេធាវីតំណាងដើមបណ្ដឹង ហើយឯកឧត្ដម ប្រធានអនុញ្ញាតឱ្យគាត់ឡើងនិយាយក្នុងនាមជាដើមបណ្ដឹង ។ លោក **សុន អរុណ** ក៏ឡើងមកសុំប្ដឹងក្រុម-ប្រឹក្សាធម្មនុញ្ញអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និងគ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ

- យល់ឃើញថា លោក **មាន សទិ** តំណាងឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយដោះសាចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំការបោះឆ្នោតស្របទៅតាមច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងទៅតាមបទបញ្ជានិងនីតិវិធីរបស់ខ្លួន
- យល់ឃើញថា ឯកឧត្ដមប្រធានបានសួរលោក **សុន អរុណ** ថាមានសាក្សីឬទេ ? ។ លោក **សុន អរុណ** បានឆ្លើយថា មានសាក្សី ១៧៦នាក់ តែមានវត្តមានតែ៩៩នាក់ទេ ។ ឯកឧត្ដមប្រធានសុំឱ្យលោក **សុន អរុណ** នាំសាក្សីម្នាក់ក្នុងខេត្តណាមួយ ក្នុងរឿងណាមួយមកបំភ្លឺក្រុមប្រឹក្សាជំនុំជម្រះអំពីភាពលំអៀងរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ប៉ុន្តែលោក **សុន អរុណ** បែរជាសួរកលិខិតចាត់តាំងមេធាវីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង លិខិតតែងតាំងតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅវិញ ។ ឯកឧត្ដមប្រធានសួរទៅតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាចុងចម្លើយឱ្យបង្ហាញសាក្សី តែលោក **មាន សទិ** បានបញ្ជាក់ថាលោកគ្មានសាក្សីទេ មានតែឯកសារនិងមន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- យល់ឃើញថា លោក **សុន អរុណ** បានលើកដៃ ហើយឡើងសួរឯកឧត្ដមប្រធានក្រុមប្រឹក្សាជំនុំជម្រះអំពីនីតិវិធីជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ ឯកឧត្ដមប្រធានបានបំភ្លឺថា នីតិវិធីជំនុំជម្រះរបស់ក្រុមប្រឹក្សា-ធម្មនុញ្ញ មានរួចហើយ
- យល់ឃើញថា លោក **សុន អរុណ** បានចោទក្រុមប្រឹក្សាធម្មនុញ្ញថាបានលាក់ទុកនីតិវិធីនេះមិនឱ្យកូនក្ដីដឹង ។ ឯកឧត្ដមប្រធានក្រុមប្រឹក្សាជំនុំជម្រះបានបំភ្លឺលោក **សុន អរុណ** ថានីតិវិធីនេះបានកសាងនិងផ្សព្វផ្សាយតាំងពីឆ្នាំ ១៩៩៨ ។ ពេលនោះមានមេធាវីម្នាក់របស់ដើមបណ្ដឹងបានលើកដៃហើយក្រោកឡើងនិយាយថាក្នុងចំណោមមេធាវីទាំង ៦នាក់ ពុំមានអ្នកណាជាប្រធានទេ
- យល់ឃើញថា ក្នុងខណៈនោះមេធាវីទាំង ៦នាក់របស់ដើមបណ្ដឹង ក៏បានក្រោកឡើងដើរចេញពីសវនាការនៅម៉ោង ៨:៣២នាទី
- យល់ឃើញថា ក្នុងពេលដំណាលគ្នានោះ ឯកឧត្ដមប្រធានក្រុមប្រឹក្សាជំនុំជម្រះបន្តនីតិវិធី ដោយសុំឱ្យសមាជិកក្រុមប្រឹក្សាជំនុំជម្រះសួរដើមចោទនិងចុងចម្លើយ។ ឯកឧត្ដម **ឡោក់ សុខ** បានសុំឱ្យលេខាអានកំណត់ហេតុសួរយកចម្លើយពីលោក **សុន អរុណ** ត្រង់ទំព័រទី៤ កាលពីថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០៣ ។ លេខាបានអានថា

លោក **សុន អរុណ** បានឆ្លើយថា ÷ " មិនប្តឹងពីលទ្ធផលនៃការបោះឆ្នោតទេ គឺប្តឹងអំពីការលំអៀងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាំងឥរិយាបថ និង ទាំងការអនុវត្តន៍របស់គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត "

- យល់ឃើញថា ទោះបីមានការដកខ្លួនថយចេញពីសវនាការរបស់មេធាវីតំណាងឱ្យដើមបណ្តឹង ក៏ក្រុមប្រឹក្សា-ជំនុំជម្រះនៅតែមានសុពលភាពគ្រប់គ្រាន់ក្នុងការបន្តនីតិវិធីជំនុំជម្រះក្នុងរឿងក្តីនេះ
- យល់ឃើញថា ពាក្យបណ្តឹងនេះ មិនប្តឹងពីលទ្ធផលនៃការបោះឆ្នោតទេ គឺប្តឹងអំពីអាកប្បកិរិយារបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតសុទ្ធសាធក្នុងការរៀបចំបោះឆ្នោត
- យល់ឃើញថា តាមមាត្រា ១២៦ ថ្មី និង វាក្យខ័ណ្ឌទី៣ នៃមាត្រា ១៥ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះ-ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការដាក់ទណ្ឌកម្មគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ
- យល់ឃើញថា ពុំមានមាត្រានៃច្បាប់ណាដែលចែងថា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវដោះស្រាយបណ្តឹងរបស់គណ-បក្សនយោបាយដែលប្តឹងពីឥរិយាបថនិងសកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាននោះទេ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចឆ្លើយតបតាមពាក្យសុំរបស់គណបក្សហ៊្វុនស៊ិនប៉ិចបានឡើយ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា១ :** ទទួលពាក្យបណ្តឹងលេខ ៦៩៧ ហសប.សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៣ របស់ស្តេចក្រុម-ឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយបណ្តឹងនេះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា២:** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០៣ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧២ /០១៦ / ២០០៣

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ : ០៥៦ /០០៧ / ២០០៣ កបធ.ច

ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះសារលិខិត របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៨១ ហសប/ជស ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៣ ផ្ទេរសិទ្ធិជូនឯកឧត្តម **ញឹក ប៊ុនឆៃ** អគ្គលេខាធិការរង គណបក្សហ៊្វុនស៊ិនប៉ិច ដើម្បីជាតំណាងក្នុងរឿងប្តឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងបណ្តឹងលេខ ៦៦៥ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៣
- បានឃើញពាក្យបណ្តឹងរបស់ឯកឧត្តម **ញឹក ប៊ុនឆៃ** អគ្គលេខាធិការរងគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៦៥ ចុះថ្ងៃទី១១ខែសីហា ឆ្នាំ២០០៣ ប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមិនបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតឱ្យស្របតាមបទបញ្ជា នីតិវិធី ក្រមសីលធម៌និងច្បាប់បោះឆ្នោត ដែលអគ្គលេខាធិការ-ដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ០៨:៣៥ នាទី
- បានឃើញលិខិតរបស់គណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៦៧ ហសប.សណ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៣

ខុទ្ទេសនាមលោក **សុន អរុណ** ជាប្រធានការិយាល័យមេធាវីនិងលោក **ម៉ី ចំន្ទទាវសនា** ជាប្រធានផ្នែករដ្ឋបាលមេធាវីរបស់គណបក្ស ដើម្បីបំពេញភារកិច្ចដាក់ពាក្យបណ្តឹង និង ទំនាក់ទំនងជាមួយក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញកំណត់ហេតុសួរយកចម្លើយ ដែលបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិចកាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ពីតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣

-បានឃើញលិខិតពឹងពាក់មេធាវី លេខ ៦៧៩ ហសប.សណ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **ញឹក ប៊ុនឆៃ** អគ្គលេខាធិការរងគណបក្សហ៊្វុនស៊ិនប៉ិច សុំឱ្យមេធាវី ៦ រូប ដើម្បីជាតំណាងក្នុងពេលសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ០៨.១៦៨៦/០៣ គ.ជ.ប ចុះថ្ងៃទី ២០ខែ សីហា ឆ្នាំ២០០៣ របស់ឯកឧត្តម **អ៊ឹម សូស្តី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់តាំងតំណាង គ ជ ប ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និង លិខិតលេខ ០៨. ១៦៩០/០៣/គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០៣ របស់ឯកឧត្តម **អ៊ឹម សូស្តី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបន្ថែមសមាជិក គ ជ ប ចំនួន ៣រូប ដើម្បីចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់ចុងចម្លើយ**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ឯកឧត្តម **ញឹក ប៊ុនឆៃ** តំណាងគណបក្សហ៊្វុនស៊ិនប៉ិច បានដាក់បណ្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញមានលក្ខណៈអាចទទួលយកមកពិនិត្យបាន ដោយផ្អែកតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-យល់ឃើញថា បណ្តឹងនេះបានដាក់ក្នុងរយៈពេល ៧២ ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-យល់ឃើញថា ការចោទប្រកាន់របស់គណបក្សហ៊្វុនស៊ិនប៉ិច ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការមិនបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតឱ្យស្របតាមបទបញ្ជា នីតិវិធី ក្រមសីលធម៌ និង ច្បាប់បោះឆ្នោតមាន ០៥ ចំណុច គប្បីយកបញ្ហាទាំងនេះមកពិចារណាបន្តបន្ទាប់តាមករណីនីមួយៗ

-យល់ឃើញថា មុនពេលយុទ្ធនាការឃោសនាបោះឆ្នោត ពុំមានច្បាប់ណាហាមឃាត់មិនឱ្យគណបក្សនយោបាយធ្វើការចែកអំណោយដល់ប្រជាពលរដ្ឋឡើយ ។ នៅពេលយុទ្ធនាការឃោសនាបោះឆ្នោតរហូត ដល់ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០០៣ មានលេចបញ្ហាចែកអំណោយដើម្បីទិញសន្លឹកឆ្នោត តែបញ្ហាទាំងនោះក៏បានត្រូវបណ្តា

គណបក្ស និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ បានដោះស្រាយមួយចំនួនហើយ ហើយមួយចំនួនទៀតពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ទេ ។ ក្នុងអង្គសវនាការជំនុំជម្រះនេះ ពុំឃើញមានភស្តុតាងអំពីបញ្ហានេះ ឱ្យបានច្បាស់លាស់ឡើយ

- យល់ឃើញថា វត្តមានអាជ្ញាធរដែនដីដូចជាអភិបាលស្រុក-ខណ្ឌ មេឃុំ ចៅសង្កាត់និងមេភូមិ ដែលនៅកន្លែងខ្លះត្រូវបានចោទប្រកាន់ថារំលោភលើសេចក្តីណែនាំរួមរបស់ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោតនោះ ត្រូវបានដោះស្រាយទៅតាមទីកន្លែងរួចស្រេចអស់ហើយ ជាមួយនឹងគណបក្សនយោបាយ គណៈកម្មការបោះឆ្នោតគ្រប់ថ្នាក់រួចហើយ
- យល់ឃើញថា បញ្ជីបោះឆ្នោតនៅការិយាល័យនានាមានការខ្វះចន្លោះ ខ្លះដោយអចេតនា ខ្លះដោយបច្ចេកទេស ប៉ុន្តែភាពមិនប្រក្រតីធ្ងន់ធ្ងរពុំកើតមានឡើយនៅទូទាំងប្រទេស
- យល់ឃើញថា ការផ្លាស់ប្តូរទីតាំងការិយាល័យ និង ការបិទផ្សាយទីតាំងការិយាល័យបោះឆ្នោត ដែលត្រូវបានចោទថា មិនអនុវត្តតាមមាត្រា៨៦ នៃច្បាប់បោះឆ្នោត និងការបិទបញ្ជីបោះឆ្នោតនៅតាមការិយាល័យមិនបានគ្រប់ ២៤ ម៉ោង មុនថ្ងៃបោះឆ្នោត ជាបណ្តឹងមិនមានមូលដ្ឋានគ្រប់គ្រាន់ លើកលែងតែករណីតិចតួច ដែលមានការប្តូរកន្លែងមុនថ្ងៃបោះឆ្នោត ទៅកន្លែងដែលជិតបំផុត ដើម្បីសម្រួលសម្រួលតាមច្បាប់ តាមការជាក់ស្តែង និងទីកលិចដែលជាករណីប្រធានស័ក្តិ ដោយមានការឯកភាពជាមួយគណបក្សនយោបាយនានា ពិសេសគណបក្សធំទាំងបី ។ អ្នកមិនបានទៅមើលឈ្មោះមុនថ្ងៃបោះឆ្នោត មានការពិបាកខ្លះ ប៉ុន្តែអាចបោះឆ្នោតបាន ។ ករណីទាំងនេះ មិនបង្កឱ្យមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ជះឥទ្ធិពលទៅលើលទ្ធផលនៃការបោះឆ្នោតទូទាំងប្រទេសឡើយ
- យល់ឃើញថា ការអះអាងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិចថាបណ្តឹងរបស់គណបក្សនេះ ត្រឹម ១ភាគ៤ តែប៉ុណ្ណោះត្រូវមន្ត្រីគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ឃុំ សង្កាត់ និង ខេត្ត ក្រុង យកមកដោះស្រាយ ឯ ៣ ភាគ ៤ ទៀតមិនបានយកមកដោះស្រាយទេ ។ បណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិចទាំងប៉ុន្មាន សុទ្ធសឹងបានពិចារណាពីខាងលើរួចហើយ នៅកន្លែងខ្លះមានភាពមិនប្រក្រតីតិចតួច ប៉ុន្តែមានមូលហេតុគ្រប់គ្រាន់ខាងផ្លូវច្បាប់ និងជាក់ស្តែង ព្រមទាំងមិនជះឥទ្ធិពលដល់លទ្ធផលនៃការបោះឆ្នោតឡើយ ។ ចំពោះបញ្ហានេះ ការដោះសារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលឆ្លើយក្នុងអង្គសវនាការ បញ្ជាក់ថា ÷ មានបណ្តឹងមួយចំនួនត្រូវបានបញ្ចប់រួចហើយ នៅត្រឹមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ឯមួយចំនួនទៀតត្រូវបានបញ្ចប់ត្រឹមគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត មានបណ្តឹងតិចតួចណាស់ដែលប្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានដោះស្រាយរួចរាល់អស់ហើយ ។ ចំពោះពាក្យបណ្តឹងដែលអះអាងថា នៅសល់បណ្តឹង ៣ ភាគ ៤ ទាក់ទងនឹងភាពមិនប្រក្រតីមិនទាន់ត្រូវបានដោះស្រាយនោះ ពុំមានភស្តុតាងគ្រប់គ្រាន់មកបញ្ជាក់នោះទេ ។

## សម្រេច

## ចំពោះមុខចុងចម្លើយ កំបាំងមុខដើមបណ្តឹង

## ប៉ុន្តែចាត់ទុកជាចំពោះមុខ

**មាត្រា ១ :** បដិសេធពាក្យបណ្តឹងរបស់ឯកឧត្តម **ញឹក ប៊ុនឆៃ** តំណាងគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៦៥ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៣ ប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលថាមិនបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតឱ្យស្របតាមបទបញ្ជា នីតិវិធី ក្រមសីលធម៌ និង ច្បាប់បោះឆ្នោត ។

**មាត្រា ២ :** បដិសេធពាក្យបណ្តឹងរបស់ឯកឧត្តម **ញឹក ប៊ុនឆៃ** ដែលទាមទារឱ្យក្រុមប្រឹក្សាធម្មនុញ្ញប្រកាសបដិសេធលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ។

**មាត្រា ៣ :** សេចក្តីសម្រេចនេះប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញថ្ងៃទី២៦ខែ សីហាឆ្នាំ២០០៣ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧១/០១៥/២០០៣

ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ : ០៥៧/០០៨/២០០៣ កបធ.ច

ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញពាក្យបណ្តឹង គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្ស សម រង្ស៊ី ប្តឹងតវ៉ាអំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ ២០០៣

-បានឃើញលិខិត គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្ស សម រង្ស៊ី ផ្ទេរសិទ្ធិឱ្យទៅឯកឧត្តម **អ៊ូ ប៊ុនឡុង** ប្រធានគណៈកម្មការបោះឆ្នោតគណបក្ស សម រង្ស៊ី ដើម្បីដាក់ពាក្យបណ្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ ជ ប ) កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ៨:៣០របស់សមាជិកក្រុមទី ២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពីឯកឧត្តម **តេព នីថា** អគ្គលេខាធិការ គ ជ ប ដើម្បីបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១៥:៣០ របស់សមាជិកក្រុមទី ២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពីលោក **លុន នេងកែ** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតក្រុងភ្នំពេញ ដើម្បីបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ៨:០០ របស់សមាជិកក្រុមទី ២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពីឯកឧត្តម **តេប នីថា** អគ្គលេខាធិការ គ ជ ប ដើម្បីបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

-បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១៥:៣០ របស់សមាជិកក្រុមទី ២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពីឯកឧត្តម **អ៊ូ ប៊ុនឡុង** ប្រធានគណៈកម្មការបោះឆ្នោតគណបក្ស សម រង្ស៊ី ដើម្បីបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

-បានឃើញលិខិតលេខ ០៨.១៦៨៦/០៣ គ ជ ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **អ៊ឹម សួស្តី** ប្រធាន គ ជ ប ដែលបានចាត់តាំងឱ្យតំណាង គ ជ ប ដើម្បីឆ្លើយបំភ្លឺនាពេលសវនាការនៅក្រុម-ប្រឹក្សាធម្មនុញ្ញ លើពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៣

-បានឃើញលិខិតលេខ ០៨.១៦៩០/០៣ គ ជ ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **អ៊ឹម សួស្តី** ប្រធាន គ ជ ប ស្តីពីការបន្ថែមសមាជិក គ ជ ប ចំនួន ៣ រូប ដើម្បីឆ្លើយបំភ្លឺនាពេលសវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ លើពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៣

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានស្តាប់សាក្សីនាំងសងខាង**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ពាក្យបណ្តឹងតវ៉ារបស់ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ ជាពាក្យបណ្តឹងដោយផ្ទាល់ក្នុងអំឡុងពេល ៧២ ម៉ោង ក្រោយពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររបស់ គ ជ ប ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទទួលបាននៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១០:៣០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់

## ករណីភ្នំពេញ (១២)

-យល់ឃើញថា ការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៣ នេះ ត្រូវធ្វើនៅទីស្នាក់ការឃុំ សង្កាត់ ខុសពីការចុះឈ្មោះបោះឆ្នោតកន្លងមក ដែលធ្វើនៅគ្រប់ការិយាល័យបោះឆ្នោតនីមួយៗ ទូទាំងប្រទេស

-យល់ឃើញថា ពេលចុះឈ្មោះបោះឆ្នោតដំបូង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ខ្លះបានចុះឈ្មោះលើសពី ៧០០ នាក់ ដែលច្បាប់កំណត់សម្រាប់មួយការិយាល័យ ។ នៅក្រោយពេលមានការណែនាំរបស់គណៈកម្មការក្រុងរៀបចំការបោះឆ្នោត ក៏មានការកែតម្រូវ ដោយបញ្ចូលឈ្មោះអ្នកចុះឈ្មោះ ទៅការិយាល័យថ្មីដែលនៅជិត ហើយដែលជាហេតុនាំឱ្យមានការប្តូរលេខបង្កាន់ដៃ និង លេខកូដការិយាល័យ ។

-យល់ឃើញថា ការសុំបញ្ជីបោះឆ្នោតដែលមិនទាន់ធ្វើបច្ចុប្បន្នភាព ហើយដែលមិនត្រូវបានផ្តល់ជូនដោយ គ ជ ប មិនពាក់ព័ន្ធដល់មាត្រា ៦៣ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

## ករណីខេត្តស្វាយរៀង (២០)

-យល់ឃើញថា គណបក្ស សម រង្ស៊ី ក្រោយពីបានទទួលទម្រង់បែបបទ ១១០៥ យកមកផ្ទៀងផ្ទាត់តួលេខ ឃើញថា មានខុសតួលេខដែលបានបូកផ្ទៀងផ្ទាត់ហើយ ក៏ប្តឹងទៅ គ ជ ប ដើម្បីផ្ទៀងផ្ទាត់ឡើងវិញលើទម្រង់បែបបទ ១១០៥ ទៅនឹងទម្រង់បែបបទ ១១០៤ ទាំង ១៤ ឃុំ នៅខេត្តស្វាយរៀង

-យល់ឃើញថា គ ជ ប យល់ព្រមឱ្យក្រុមត្រួតពិនិត្យធ្វើការផ្ទៀងផ្ទាត់ចំនួន ១៤ ឃុំ តាមបណ្តឹងរបស់គណបក្ស សម រង្ស៊ី ដោយមានតំណាងគណបក្ស និង អ្នកសង្កេតការណ៍ចំនួន ១៤ រូប ចូលរួមផង

-យល់ឃើញថា មន្ត្រីគណៈកម្មការឃុំរៀបចំការបោះឆ្នោត មានការធ្វេសប្រហែសក្នុងការស្រង់តួលេខចូលក្នុងទម្រង់បែបបទ ១១០៥ ដោយមិនបានផ្ទៀងផ្ទាត់ជាមួយទម្រង់បែបបទ ១១០៣ ឱ្យបានត្រឹមត្រូវ បណ្តាលឱ្យមានការភ័ន្តច្រឡំតួលេខនៃគណបក្សតូចៗ ។ ប៉ុន្តែការភ័ន្តច្រឡំនេះ មិនបណ្តាលឱ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោតទេ

-យល់ឃើញថា លទ្ធផលដែលគណបក្ស សម រង្ស៊ី ចាញ់គេមាន ១៤៦ សំលេង គឺត្រូវជា 0.06% នឹងទទួលបានមួយអាសនៈ ហើយទាមទារឱ្យរាប់ និង ផ្ទៀងផ្ទាត់ឡើងវិញនោះ មិនសមស្របទេ

-យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនមានចែងឱ្យមានការរាប់ និង ផ្ទៀងផ្ទាត់ឡើងវិញ ដោយសារការប្រៀបធៀបមធ្យមភាគធំដែលគណបក្សនយោបាយបានទទួលនោះទេ

-យល់ឃើញថា មានតួលេខខុសគ្នាពីលទ្ធផលបណ្តោះអាសន្នប្រកាសនៅគណៈកម្មការឃុំរៀបចំការបោះឆ្នោត និង ខុសពីទម្រង់បែបបទ ១១០៥ ជាមួយនឹងលទ្ធផលបណ្តោះអាសន្នប្រកាសជាផ្លូវការដោយ គ.ជ.ប និង

បណ្តាលមកពីការខ្វះខាតរបស់គណៈកម្មការឃុំរៀបចំការបោះឆ្នោត ស្រង់តួលេខចូលទម្រង់បែបបទ ១១០៥ ប៉ុន្តែទម្រង់បែបបទ ១១០៣ មិនមានខុសទេ ។ ការខុសឆ្គងនេះត្រូវបានកែតម្រូវឡើងវិញ បន្ទាប់ពីក្រុមត្រួតពិនិត្យ គ.ជ.ប រកឃើញការខ្វះខាតទាំងនេះ

-យល់ឃើញថា គណៈកម្មការឃុំរៀបចំការបោះឆ្នោត ឃុំដូង (០៣៩) ចេញទម្រង់បែបបទ ១១០៥ ដល់ទៅពីរច្បាប់ ហើយតួលេខខុសគ្នា នេះជាការខ្វះខាតរបស់គណៈកម្មការឃុំរៀបចំការបោះឆ្នោតដែរ ប៉ុន្តែមូលហេតុសំខាន់គឺ ទម្រង់បែបបទ ១១០៥ នេះត្រូវបានកែតម្រូវឡើងវិញក្រោយពេលពិនិត្យផ្ទៀងផ្ទាត់រួចមក ។ ចំពោះទម្រង់បែបបទ ១១០៣ គឺត្រឹមត្រូវដដែល ។

-យល់ឃើញថា លើទម្រង់បែបបទ ១១០៤ (កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់) នីមួយៗ ឃើញថា នៅក្រុមរាប់សន្លឹកឆ្នោតទូទាំង ១៥ ឃុំ មានចុះហត្ថលេខាលើទំរង់បែបបទ ១១០៤ ពីតំណាងគណបក្សនានា ក្នុងនោះមានតំណាងគណបក្ស សម រង្ស៊ី ដែរ លើកលែងតែក្រុមរាប់សន្លឹកឆ្នោតចំនួន ៥ ក្រុម ដូចជា :

-ឃុំប្រសូតិ ក្រុមរាប់មាន ៣ ក្រុមរាប់ទី ១ និង ទី ៣មានចុះហត្ថលេខារួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ២ មិនមានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ប៉ុន្តែពុំមានពាក្យបណ្តឹងអ្វីទាំងអស់

-ឃុំដូង ក្រុមរាប់មាន ៤ ក្រុមរាប់ទី ១ ទី ២ និង ទី ៣ មានចុះហត្ថលេខា រួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ៤ មិនមានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី

-ឃុំច្រកម្ទេសក្រុមរាប់មាន ៤ ក្រុមរាប់ទី ២ ទី ៣ និង ទី ៤ មានចុះហត្ថលេខាតំណាងគណបក្សនានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ១ មិនមានតំណាងគណបក្សនយោបាយណាចុះហត្ថលេខាទេ

-ឃុំញរ ក្រុមរាប់មាន ៣ ក្រុមរាប់ទី ១ និង ទី ៣ មានចុះហត្ថលេខាតំណាងគណបក្សនយោបាយនានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី ផង លើកលែងតែក្រុមរាប់ទី ២ គ្មានចុះហត្ថលេខាទេ

-ឃុំត្រពាំងស្តៅ ក្រុមរាប់ទី ២ តំណាងគណបក្ស សម រង្ស៊ី មិនបានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ មែន តែក្នុងទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាដោយតំណាងគណបក្ស សម រង្ស៊ី ដែរ

-យល់ឃើញថា លើទម្រង់បែបបទ ១១០៨ ទាំង ១៥ ឃុំ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញ មានចុះហត្ថលេខារបស់តំណាងគណបក្សនានា រួមទាំងហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ផង លើកលែងតែនៅ :

-ឃុំប្រសូតិ ក្រុមរាប់ទី ២ គ្មានចុះហត្ថលេខារបស់តំណាងគណបក្ស សម រង្ស៊ី ទេ

-ឃុំដូង ក្រុមរាប់ទី ២ និង ទី ៣ គ្មានចុះហត្ថលេខារបស់តំណាងគណបក្ស សម រង្ស៊ី ទេ តែក៏គ្មានពាក្យបណ្តឹងអ្វីដែរ ក៏ប៉ុន្តែនៅលើទម្រង់បែបបទ ១១០៩ និង ទម្រង់បែបបទ ១១០៣ មានហត្ថលេខារបស់

តំណាងគណបក្ស សម រង្ស៊ី ដែរ

-នៅឃុំច្រកម្ទេស ក្រុមរាប់ទី ១ មិនបានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ មែន តែក្នុងទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

-នៅឃុំញរ ក្រុមរាប់ទី ២ មិនបានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ មែន តែក្នុងទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

-យល់ឃើញថា លើទម្រង់បែបបទ ១១០៣ ទាំង ១៥ ឃុំ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញ មានចុះហត្ថលេខារបស់តំណាងគណបក្សនានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែឃុំប្រសូតិ (០៧៦) ដែលគ្មានតំណាងគណបក្សណាមួយចុះហត្ថលេខាទេ ប៉ុន្តែក៏គ្មានពាក្យបណ្តឹងដែរ

-យល់ឃើញថា លើទម្រង់បែបបទ ១១០៩ ទាំង ១៥ ឃុំ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញ ឃើញថា :

-ឃុំប្រសូតិ (០៧៦) គ្មានហត្ថលេខាតំណាងគណបក្សណាទេ

-ឃុំកំពង់ចក (០២៥) មិនមានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ីទេ ប៉ុន្តែក្នុងទម្រង់បែបបទ ១១០៨ មានហត្ថលេខាតំណាងគណបក្សនានា រួមទាំងហត្ថលេខាតំណាងគណបក្ស សម រង្ស៊ីផង ហើយក្នុងទម្រង់បែបបទ ១១០៣ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី រហូតដល់ ៣ នាក់

-ឃុំថ្មី (០២១) គ្មានតំណាងគណបក្សនយោបាយណាមួយចុះហត្ថលេខាទេ ប៉ុន្តែក្នុងទម្រង់បែបបទ ១១០៨ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

-ឃុំត្រពាំងស្ដៅ (០៤៧) គ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ទេ ប៉ុន្តែក្នុងទម្រង់បែបបទ ១១០៣ និង ទម្រង់បែបបទ ១១០៨ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

-យល់ឃើញថា ទម្រង់បែបបទ ១១០៣ ទាំង ១៥ ឃុំ ដែលស្នើឱ្យរាប់ឡើងវិញ ជាឯកសារសំខាន់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ហើយក្នុងទម្រង់បែបបទទាំងនោះ មានចុះហត្ថលេខាដោយតំណាងគណបក្សនានា រួមទាំងហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី លើកលែងតែ ឃុំប្រសូតិ (០៧៦) តែមួយគត់ ដែលគ្មានហត្ថលេខារបស់តំណាងគណបក្សណាទាំងអស់ ។ ការខ្វះខាតនានា ដែលបានលើកឡើង រួមមានការខ្វះខាតក្នុងការស្រង់តួលេខដាក់ចូលក្នុងទម្រង់បែបបទ ១១០៥ (ក្រដាសលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់) សម្រាប់ជូនគណបក្សនានា វាមិនអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោតទេ

-យល់ឃើញថា ក្នុងចំណោមឃុំទាំង ១៥ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញនោះ តំណាងគណបក្ស សម រង្ស៊ី ខ្លួនឯង សុទ្ធតែបានចុះហត្ថលេខាទទួលស្គាល់តួលេខត្រឹមត្រូវអស់ហើយ ដោយមានចុះហត្ថលេខានៅ

លើទម្រង់បែបបទ ខ្ទះលេខ ១១០៨ ខ្ទះលេខ ១១០៩ ខ្ទះលេខ ១១០៤ ហើយនិងខ្ទះទៀតលេខ ១១០៣ ។

-យល់ឃើញថា លើទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាតំណាងគណបក្សនានា រួមទាំងគណបក្ស សម រង្ស៊ី ផង លើកលែងតែឃុំប្រសូតិ (០៧៦) មួយ គឺជាការទទួលស្គាល់ការបូកសរុបលទ្ធផលនៃការបោះឆ្នោតទាំង ១៥ ឃុំ ដែលប្ដឹងឱ្យរាប់ឡើងវិញ ។ ដូច្នេះការស្នើឱ្យរាប់ឡើងវិញមិនជាការចាំបាច់ទេ ។

## ករណីខេត្តកំពង់ធំ (០៦)

-យល់ឃើញថា គណបក្ស សម រង្ស៊ី បានប្ដឹងមកគណៈកម្មការខេត្តរៀបចំការបោះឆ្នោត (គ ខ ប) ចំនួន ២៣ បណ្ដឹងក្នុងខេត្តកំពង់ធំ ។ ចំពោះបណ្ដឹងសុំឱ្យរាប់ឡើងវិញ ៦ ឃុំ គ ខ ប បានឱ្យតំណាងគណបក្ស សម រង្ស៊ី ជ្រើសរើស ២ ឃុំ ដែលសង្ស័យថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ។ តំណាងគណបក្ស សម រង្ស៊ី បានឯកភាពជាមួយ គ ខ ប ដោយឱ្យផ្ទៀងផ្ទាត់ និង រាប់សន្លឹកឆ្នោតខូចនៅឃុំដូង (០៣៩) និង រាប់ឡើងវិញនៅឃុំសាគ្រាម (០៤២) ។ ចំពោះបណ្ដឹងសុំឱ្យផ្ទៀងផ្ទាត់ចំនួន ១៤ ឃុំ គ ខ ប បានធ្វើការផ្ទៀងផ្ទាត់ចំនួន ៦ ឃុំ គឺ ឃុំក្រវ៉ាញ (០១១) ឃុំព្នៅ (០៦៥) ឃុំគគីរ (០១០) ឃុំពង្រ (០១៣) ឃុំប្រទាង (០០៦) និង ឃុំដូង (០៣៩) ពុំឃើញមានភាពមិនប្រក្រតីគួរឱ្យកត់សំគាល់ឡើយ

-យល់ឃើញថា គណបក្ស សម រង្ស៊ី បានប្ដឹងមក គ ជ ប ដោយសុំឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួន ២៦ ឃុំ ហើយ គ ជ ប សំរេចធ្វើការផ្ទៀងផ្ទាត់ចំនួន ១១ ឃុំ គឺ ឃុំស្វាយភ្លើង (០១៦) ឃុំកំពង់ធំ (០២៩) ឃុំក្ដីដូង (០៣២) ឃុំក្រយា (០៤០) ឃុំទួលគ្រើល (០៤៥) ឃុំចំណារក្រោម (០៧០) ឃុំព្រះដំរី (០៧៨) ឃុំសំព្រោជ (០៨០) មានការខុសគួលេខបន្តិចបន្តួច ហើយបានឯកភាពគ្នាកែតម្រូវរួចហើយ ។ ចំពោះ ៣ ឃុំទៀតគឺ ឃុំបាក់ស្នា (០០១) ឃុំសណ្ដាន់ (០៥៧) ឃុំកកោះ (០៦៣) គ្មានអ្វីគួរឱ្យកត់សំគាល់ពីភាពមិនប្រក្រតីឡើយ ដោយក្នុងទម្រង់ ១១០៨ ទម្រង់ ១១០៤ ទម្រង់ ១១០៩ ទម្រង់ ១១០៣ និង ទម្រង់ ១១០៥ ក្នុងពេលផ្ទៀងផ្ទាត់ មានលក្ខណៈត្រឹមត្រូវទាំងអស់ ហើយក្នុងពេលផ្ទៀងផ្ទាត់នោះ ក៏មានការចូលរួមពីតំណាងគណបក្ស សម រង្ស៊ី និង អង្គការដទៃទៀត តែពុំបានដាក់ចូលក្នុងកំណត់ហេតុ គឺជាការខ្វះខាតមួយរបស់ក្រុមត្រួតពិនិត្យ គ ជ ប

-យល់ឃើញថា ការរាប់សាកល្បងរបស់ គ ខ ប ចំនួន ២ ឃុំ គឺ ឃុំដូង (០៣៩) បានផ្ទៀងផ្ទាត់ និង រាប់សន្លឹកឆ្នោតខូច និង ឃុំសាគ្រាម (០៤២) រាប់ឡើងវិញតាមពាក្យបណ្ដឹងរបស់លោក **ម៉ៅ សុភារិទ្ធ** តំណាងគណបក្ស សម រង្ស៊ី ដែលប្ដឹងសុំឱ្យរាប់ឡើងវិញចំនួន ៦ ឃុំ រួមមាន : ឃុំដាន់ញ៉ឹម (០៤១) ឃុំដូង (០៣៩) ឃុំគោល (០៤៧) ឃុំសណ្ដាន់ (០៥៧) ឃុំជ្រាប់ (០៦១) និង ឃុំសាគ្រាម (០៤២) មិនឃើញមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់លទ្ធផលបោះឆ្នោតទេ

-យល់ឃើញថា សន្លឹកឆ្នោតដែលលើស ៦៣ សន្លឹក បណ្តាលមកពីការស្រង់លេខច្រឡំក្នុងទម្រង់ ១១០៥ ដោយសន្លឹកឆ្នោតខូចមានចំនួន ១៨ សន្លឹក តែសរសេរ ៨១ សំលេង (៨១-១៨ = ៦៣) គឺជាការខ្វះខាតមួយរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គ ឃ ប)

-យល់ឃើញថា ក្នុងទម្រង់បែបបទ ១១០៤ មានហត្ថលេខានានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី ផងដែរ លើកលែងតែ ក្រុមរាប់មួយចំនួនគ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដូចជា : ឃុំបន្ទាយស្មោង ក្រុមរាប់ទី ១ ទី ២ ទី ៤ ឃុំចុងដូង ក្រុមរាប់ទី ១ ឃុំងន ក្រុមរាប់ទី ១ ឃុំសាលាវិស័យ ក្រុមរាប់ទី ១ ឃុំសណ្តាន់ ក្រុមរាប់ ទី ៤

-យល់ឃើញថា ក្នុងទម្រង់បែបបទ ១១០៨ ដែលក្រុមត្រួតពិនិត្យ គ ជ ប បានពិនិត្យឡើងវិញចំនួន ១១ ឃុំ ក្នុងចំណោម ២៦ ឃុំ ដែលសុំឱ្យផ្ទៀងផ្ទាត់ឡើងវិញ ដោយគណបក្ស សម រង្ស៊ី នោះ ឃើញថា មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ៣ ឃុំចំណារក្រោម (០៧០) ដែលមាន ៤ ក្រុមរាប់ ដែលគ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ប៉ុន្តែលើទម្រង់បែបបទ ១១០៩ នៃឃុំទាំងនេះ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

-យល់ឃើញថា លើទម្រង់បែបបទ ១១០៣ ទាំង ៣៩ ឃុំ ឃើញថាមានហត្ថលេខា ៣៨ ឃុំ ដែលមានហត្ថលេខារបស់តំណាងគណបក្សនានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី ។ ដោយឡែកឃុំចំណារក្រោម (០៧០) មាន ៤ ក្រុមរាប់តែក្រុមរាប់ទី ៣ គ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ប៉ុន្តែនៅលើទម្រង់បែបបទ ១១០៩ នៃឃុំទាំងនេះ មានហត្ថលេខាគណបក្ស សម រង្ស៊ី ដែរ

-យល់ឃើញថា ក្នុងទម្រង់បែបបទ ១១០៩ ដែលក្រុមត្រួតពិនិត្យ គ ជ ប បានពិនិត្យឡើងវិញចំនួន ១១ ឃុំ ក្នុងចំណោម ២៦ ឃុំ ដែលសុំឱ្យផ្ទៀងផ្ទាត់ឡើងវិញ ដោយគណបក្ស សម រង្ស៊ី នោះ ឃើញថា មានតំណាងគណបក្សនានាចុះហត្ថលេខា រួមទាំងតំណាងគណបក្ស សម រង្ស៊ី ដែរ

-យល់ឃើញថា ទម្រង់បែបបទ ១១០៣ ជាឯកសារសំខាន់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលនៃការបោះឆ្នោតខេត្ត ក្រុង មានចុះហត្ថលេខាទទួលស្គាល់ដោយតំណាងគណបក្សនានា រួមទាំងគណបក្ស សម រង្ស៊ី ផង លើកលែងតែឃុំកំពង់ចិនត្បូង (០៧៣) មួយ ប៉ុន្តែតំណាងគណបក្ស សម រង្ស៊ី បានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ ដែរ ។ ដូច្នេះការស្នើឱ្យរាប់ឡើងវិញ មិនជាការចាំបាច់ទេ ។

## ករណីខេត្តបន្ទាយមានជ័យ (០១)

-យល់ឃើញថា មានអ្នកបោះឆ្នោតនៅឃុំប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ មានអត្រាត្រឹម ៤៦% យើងទទួលស្គាល់ថា តិចមែន បើប្រៀបធៀបនឹងអត្រាទូទាំងខេត្ត ដែលមាន ៧៤% ប៉ុន្តែ ក្នុងច្បាប់បោះឆ្នោត

ជ្រើសតាំងតំណាងរាស្ត្រ ពុំមានកំណត់ថា តើអត្រាអ្នកបោះឆ្នោតប៉ុន្មានអាចទទួលយកបាន អត្រាអ្នកបោះឆ្នោតប៉ុន្មាន មិនអាចទទួលយកបាន ព្រោះប្រជាពលរដ្ឋ មានសិទ្ធិទៅបោះឆ្នោត ដែលធានាដោយច្បាប់ មិនមែនជាកាតព្វកិច្ចដែលតម្រូវចាំបាច់ត្រូវតែទៅបោះឆ្នោតទេ។ ចំណុចនេះ មានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ " ប្រជាពលរដ្ឋទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។ "

-យល់ឃើញថា ការិយាល័យបោះឆ្នោតចំនួន ២៧ បានប្តូរទៅកន្លែងផ្សេងទៀត តាំងតែពីឆ្នាំ ២០០២ ម្ល៉េះ ។ ដូច្នេះមានពេលវេលាគ្រប់គ្រាន់ ក្នុងការផ្សព្វផ្សាយជូនសាធារណជន និង បានបិទផ្សាយត្រឹមត្រូវស្របតាម មាត្រា ១៣៥ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយយោងតាមការបញ្ជាក់របស់អ្នកស្រី **ឡាយ ហ៊ុនគី** ប្រធានគណៈកម្មការខេត្តរៀបចំការបោះឆ្នោតខេត្តបន្ទាយមានជ័យ នៅក្នុង សវនាការ គ ជ ប

-យល់ឃើញថា ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំប៉ោយប៉ែត មិនមានចម្ងាយលើសពី ៥ គីឡូម៉ែត្រ ទេ តាមការបញ្ជាក់ពីឈ្មោះ **មាន សារិត** ដើមចោទមកពីគណបក្ស សម រង្ស៊ី ដែលបានអះអាងក្នុងសវនាការ គ ជ ប និង តាមការបញ្ជាក់ពីលោក **សាន ស៊ានហូ** ជូសមេឃុំប៉ោយប៉ែត កាលពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣

-យល់ឃើញថា ឈ្មោះអ្នកបោះឆ្នោតខ្លះ ពុំមានភូមិនៅក្នុងឃុំប៉ោយប៉ែតទេ បញ្ហានេះមាន តាមការដោះសារបស់ គ ជ ប ជាកំហុសបច្ចេកទេស

-យល់ឃើញថា អ្នកមានប័ណ្ណបោះឆ្នោតឆ្នាំ ២០០២ ឬ លិខិតបញ្ជាក់អត្តសញ្ញាណ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៣ មិនបានបោះឆ្នោត ដោយលើកជាភស្តុតាង ៤ នាក់ នោះ តាមការពិនិត្យយើងឃើញម្នាក់ក្នុង ៤ នាក់ គឺឈ្មោះ **គ្មៀន សារិន** ក្នុងប័ណ្ណបោះឆ្នោតទៅជាឈ្មោះ **គៀម សារិន** ក្នុងបញ្ជីបោះឆ្នោតរបស់ គ ជ ប

-យល់ឃើញថា អ្នកផ្តិតមេដៃ ៥៥៤ នាក់ សុំតវ៉ាឱ្យបោះឆ្នោតឡើងវិញ ដោយសំអាងមូលហេតុជាច្រើន ដូចជា រកការិយាល័យមិនឃើញ គេមិនឱ្យកន្ទុយប័ណ្ណ បាត់ឈ្មោះ ។ល។ ភាគច្រើន គឺរកការិយាល័យមិនឃើញ ចំណុចនេះ ក៏ជាការខ្វះខាតរបស់សាមីខ្លួនដែរ ព្រោះស្ថានភាពសន្តិសុខល្អជាធម្មតា

-យល់ឃើញថា ការចោទថា សមត្ថកិច្ចមិនព្រមប្រគល់ទម្រង់បែបបទ ១០១៨ តាមការអះអាងរបស់ឈ្មោះ **ម៉ុត ស៊ីលន** ជាការមិនពិតទេ ព្រោះអ្នកចុះឈ្មោះបោះឆ្នោតដែលមានទម្រង់បែបបទ ១០១៨ នេះមាន ៣.២១០ នាក់។ ហើយអ្នកមកយកទម្រង់នេះ មានតែជាង ២.០០០ នាក់ប៉ុណ្ណោះ អ្នកឯទៀតមិនបានមកយក

ទេ ដោយមូលហេតុ អ្នកចុះឈ្មោះខ្លះត្រឡប់ទៅស្រុកកំណើតវិញ អ្នកខ្លះស្លាប់ អ្នកខ្លះចុះឈ្មោះរួចមួយចំនួនទៅរកស៊ីនៅប្រទេសថៃ ។ ក្នុងពេលចុះឈ្មោះនោះ ក៏ចំពេលមានព្រឹត្តិការណ៍វាយស្ថានទូតថៃ និង ក្រុមហ៊ុនថៃ បណ្តាលឱ្យមានការបិទព្រំដែន ។ ពលករដែលត្រឡប់មកពីប្រទេសថៃ ត្រូវសកម្មជនគណបក្សខ្លះ ប្រកួកប្រកាសឱ្យទៅចុះឈ្មោះបោះឆ្នោតតាមវិធីលើកទឹកចិត្តផ្សេងៗ ។ ដល់ពេលព្រំដែនបើកឡើងវិញ ពលករភាគច្រើនបានទៅធ្វើការនៅប្រទេសថៃ ហើយមិនបានមកបោះឆ្នោតទេ

-យល់ឃើញថា ការសុំបញ្ជីបោះឆ្នោតដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព ហើយដែលមិនត្រូវបានផ្តល់ជូនដោយ គ ជ ប មិនពាក់ព័ន្ធដល់មាត្រា ៦៣ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

-យល់ឃើញថា យោងទៅលើមូលហេតុ និង ឯកសារដែលជាភស្តុតាងខាងលើ មិនអាចចាត់ថា ការបោះឆ្នោតនៅឃុំប៉ោយប៉ែត មានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យមានការបោះឆ្នោតសាឡើងវិញទេ ។

**ហេតុដូច្នេះ**

**សម្រេចចំពោះមុខគូភាគី**

**មាត្រា ១.-** ទទួលពាក្យបណ្តឹងតវ៉ារបស់ឯកឧត្តម **សម រង្ស៊ី** ចំពោះករណីរាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តំកល់សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៣ លេខ ០៨.៥០៤/០៣គ ជ ប ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ ទុកជាត្រឹមត្រូវទាំងមូល ។

**មាត្រា ៣.-** សេចក្តីសំរេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៦០..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ,ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ,ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.៩៦៩.២០៣.០០០ រៀល ( បួនពាន់ ប្រាំបួនរយហុកសិបប្រាំបួនលាន ពីររយបីពាន់រៀលគត់ ) ពីជំពូក ១៣ ( សកម្មភាពនៃកម្មវិធី ) ដែលមានផ្នែកអប់រំ ចំនួន ៤,៤៩៣,៧៥៨,០០០ រៀល (បួនពាន់ បួនរយកៅសិបបីលាន ប្រាំពីររយហាសិបប្រាំបីពាន់រៀលគត់ ) ផ្នែកឧត្តមសិក្សា ចំនួន ៣៧៣,១៨០,០០០រៀល ( បីរយចិតសិបបីលាន មួយរយប៉ែតសិបពាន់រៀលគត់ ) និងពីផ្នែកយុវជន និងកីឡា ចំនួន ១០២,២៦៥,០០០រៀល (មួយរយពីរលាន ពីររយហុកសិបប្រាំពាន់រៀលគត់ )មកជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងអប់រំ យុវជន និង កីឡា ( ផ្នែកអប់រំ ) សំរាប់ ការគ្រប់គ្រង ឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បង្គ្រប់ការចំណាយប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិឆ្នាំសិក្សា ២០០២-២០០៣ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ក្រមសីលធម៌គ្រូពេទ្យ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ មួយដើម្បីប្រមូលផ្តុំគ្រូពេទ្យទាំងអស់ ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែ សីហា ឆ្នាំ ២០០៣

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់បទប្បញ្ញត្តិ ស្តីពីក្រមសីលធម៌ចំពោះគ្រូពេទ្យ និងនិស្សិតក្នុងវិស័យវេជ្ជសាស្ត្រ ដែលអាចធ្វើការជំនួសគ្រូពេទ្យដែលកំពុងប្រកបវិជ្ជាជីវៈទូទាំងព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ២

## ករណីយកិច្ចទូទៅរបស់គ្រូពេទ្យ

**មាត្រា ២.**

ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ ទោះក្នុងលក្ខណៈជាឯកជនក្តី ជាសាធារណៈក្តី គ្រូពេទ្យត្រូវតែគោរព ជីវិត រាងកាយ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ។

**មាត្រា ៣.-**

ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ គ្រូពេទ្យត្រូវតែគោរពគោលការណ៍សីលធម៌ មានជាអាទិ៍ ភាពសុចរិត ភក្តីភាពចាំបាច់ ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ ។

**មាត្រា ៤.-**

ដើម្បីផលប្រយោជន៍របស់អ្នកជំងឺ គ្រូពេទ្យត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈក្នុងល័ក្ខខ័ណ្ឌដែលបានកំណត់ដោយច្បាប់ ។

**មាត្រា ៥.-**

គ្រូពេទ្យមិនត្រូវបោះបង់ឥស្សរភាពវិជ្ជាជីវៈរបស់ខ្លួនជាដាច់ខាត ទោះស្ថិតនៅក្រោមរូបភាពណាក៏ដោយ ។

**មាត្រា ៦.-**

គ្រូពេទ្យត្រូវគោរពសិទ្ធិរបស់អ្នកជំងឺ ក្នុងការជ្រើសរើសដោយសេរីនូវគ្រូពេទ្យរបស់ខ្លួន ។ គ្រូពេទ្យត្រូវជួយសម្រួលដល់ការជ្រើសរើសនេះ ។

**មាត្រា ៧.-**

គ្រូពេទ្យត្រូវស្តាប់ ពិនិត្យ ឱ្យដំបូន្មាន ឬព្យាបាល ដោយសម្បជញ្ញៈ ចំពោះមនុស្សទូទៅស្មើៗគ្នា ដោយមិនប្រកាន់អំពីប្រភព ប្រពៃណី ស្ថានភាពគ្រួសារ ជាតិសាសន៍ សាសនា កេរ្តិ៍ឈ្មោះ ឬមនោសញ្ចេតនាអ្វីឡើយ ។

ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ គ្រូពេទ្យមិនត្រូវបោះបង់ អាកប្បកិរិយា សុភាពរាបសា ត្រឹមត្រូវ និងត្រូវយកចិត្តទុកដាក់ជួយទំនុកបម្រុងចំពោះមនុស្សដែលខ្លួនពិនិត្យ ។

**មាត្រា ៨.-**

ក្នុងក្របខ័ណ្ឌច្បាប់ គ្រូពេទ្យមានឥស្សរភាពគ្រប់គ្រាន់ ក្នុងការចេញវេជ្ជបញ្ជា ដែលយល់ឃើញថា ត្រឹមត្រូវបំផុតចំពោះកាលៈទេសៈ ។

នៅក្នុងមនសិការវិជ្ជាជីវៈ គ្រូពេទ្យត្រូវកំណត់វេជ្ជបញ្ជា និង ធ្វើតែអ្វីដែលចាំបាច់សម្រាប់ធានាគុណភាព សុវត្ថិភាព និង ប្រសិទ្ធភាពនៃការថែទាំប៉ុណ្ណោះ ។

គ្រូពេទ្យត្រូវតែគិតគូរដល់អត្ថប្រយោជន៍ ដល់ផលអាក្រក់ និង ផលវិបាកទាំងឡាយ ដែលអាចកើតមានឡើងជាយថាហេតុ ក្នុងពេលធ្វើការស្រាវជ្រាវវេជ្ជសាស្ត្រ និង ក្នុងការព្យាបាល ។

**មាត្រា ៩.-**

គ្រូពេទ្យដែលនៅចំពោះមុខអ្នកជំងឺ ឬអ្នករបួសធ្ងន់ ត្រូវជួយសង្គ្រោះអ្នកទាំងនោះ ឬធ្វើយ៉ាងណាឱ្យអ្នកទាំងនោះ បានទទួលការថែទាំទាំងឡាយណា ដែលចាំបាច់បំផុត ។

**មាត្រា ១០.-**

គ្រូពេទ្យដែលសុំឱ្យពិនិត្យ ឬព្យាបាលជនដែលបាត់បង់សេរីភាព មិនត្រូវបង្កលក្ខណៈ ឬឃុបឃិតធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ ខាងផ្លូវចិត្ត ឬកិត្តិយសរបស់អ្នកជំងឺ ទោះជាដោយផ្ទាល់ ឬដោយប្រយោល ។ បើសង្កេតឃើញថា ជននោះបានទទួលការធ្វើបាបផ្សេងៗ គ្រូពេទ្យត្រូវជូនព័ត៌មាននេះទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្រោយពីបានការយល់ព្រមពីសាមីជន ។

**មាត្រា ១១.-**

គ្រូពេទ្យទាំងអស់ត្រូវតែសម្រិតសម្រាំង និងបង្កើនចំណេះដឹងរបស់ខ្លួនជានិច្ច ។ គ្រូពេទ្យត្រូវតែចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជានិរន្តរ៍ ។ គ្រូពេទ្យទាំងអស់ ត្រូវចូលរួមធ្វើការវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈ ។

**មាត្រា ១២.-**

គ្រូពេទ្យត្រូវតែគាំទ្រសកម្មភាពការពារ និងអប់រំសុខភាពរបស់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ។ ការស្រង់ ការចុះបញ្ជី ការធ្វើវិភាគ និងការបញ្ជូនព័ត៌មានដោយរាយនាម ឬរាយនាមដោយប្រយោល អាចធ្វើទៅបានតែក្នុងក្របខ័ណ្ឌកំណត់ដោយច្បាប់ ។

**មាត្រា ១៣.-**

គ្រូពេទ្យ នៅពេលដែលបានចូលរួមក្នុងការផ្តល់ព័ត៌មានស្តីអំពីការអប់រំសុខភាពសាធារណៈ តាមមធ្យោបាយផ្សព្វផ្សាយអ្វីក៏ដោយ ត្រូវតែនិយាយស្តីដោយប្រុងប្រយ័ត្ន និងគិតទៅដល់ប្រតិឃាតនៃពាក្យសំដីរបស់ខ្លួន ចំពោះសាធារណជន ។ ហេតុនេះគ្រូពេទ្យត្រូវលើកឡើងតែទិន្នន័យទាំងឡាយណាដែលមានការបញ្ជាក់ច្បាស់លាស់ ។ គ្រូពេទ្យត្រូវជៀសវាងអំពើឃោសនាសម្រាប់ខ្លួនឯងផ្ទាល់ សម្រាប់អង្គភាពដែលខ្លួនធ្វើការជាមួយ ឬ ដែលខ្លួនគាំទ្រ ឬ សំរាប់មូលហេតុអ្វីមួយដែលមិនមែនជាផលប្រយោជន៍សាធារណៈ ។

**មាត្រា ១៤.-**

គ្រូពេទ្យទាំងឡាយមិនត្រូវផ្សព្វផ្សាយ នៅក្នុងមជ្ឈដ្ឋានសុខាភិបាល អំពីវិធីធ្វើរោគវិនិច្ឆ័យណាមួយ ឬវិធីព្យាបាលណាមួយ ដែលពុំមានការបញ្ជាក់ច្បាស់លាស់ និងដោយមិនបានភ្ជាប់នូវព័ត៌មានបញ្ជាក់បម្រុងឡើយ ។ គ្រូពេទ្យមិនត្រូវធ្វើការផ្សព្វផ្សាយរបៀបនេះនៅចំពោះមុខសាធារណជន ដែលមិនមែនក្នុងក្របខ័ណ្ឌសុខាភិបាលជាដាច់ខាត ។

**មាត្រា ១៥.-**

គ្រូពេទ្យអាចចូលរួមធ្វើការស្រាវជ្រាវជីវៈវេជ្ជសាស្ត្រទៅលើមនុស្សបានតែនៅក្នុងក្របខ័ណ្ឌកំណត់ដោយច្បាប់ ។ គ្រូ

ពេទ្យត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីនិយ័តភាព និងភាពសមស្រប ព្រមទាំងភាពជាក់ស្តែងនៃសេចក្តីសន្និដ្ឋានចុងក្រោយរបស់ការស្រាវជ្រាវនោះ ។ គ្រូពេទ្យព្យាបាល ដែលបានចូលរួមក្នុងការស្រាវជ្រាវជីវៈវេជ្ជសាស្ត្រនោះ ត្រូវឃ្លាំមើលយ៉ាងណាកុំឱ្យលទ្ធផលនៃការស្រាវជ្រាវ អាចធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកជំងឺ មកលើគ្រូពេទ្យ ព្រមទាំងនិរន្តរភាពនៃការព្យាបាល ។

**មាត្រា ១៦.-**

ការបូមយកឈាម ព្រមទាំងការកាត់យកសរីរាង្គ ជាលិកា កោសិកា ឬផ្នែកផ្សេងៗទៀតណាមួយនៃរាងកាយ ទៅលើមនុស្សមានជីវិត ឬមនុស្សស្លាប់ នឹងអាចធ្វើទៅបានតែក្នុងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ ។

**មាត្រា ១៧.-**

គ្រូពេទ្យអាចបញ្ឈប់ការមានគភ៌ដោយស្ម័គ្រចិត្តបាន តែក្នុងករណី និងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ ។ គ្រូពេទ្យមានសេរីភាពជានិច្ចក្នុងការមិនទទួលធ្វើតាមសំណូមពរ ហើយត្រូវជូនដំណឹងដល់សាមីខ្លួនទៅតាមល័ក្ខខ័ណ្ឌ និងរយៈពេលកំណត់ដោយច្បាប់ ។

**មាត្រា ១៨.-**

វិជ្ជាជីវៈវេជ្ជសាស្ត្រ មិនត្រូវបានអនុញ្ញាតឱ្យយកទៅច្នៃប្រឌិតធ្វើជាមុខជំនួញផ្ទាល់ខ្លួនណាមួយឡើយ ។ រូបភាពផ្សព្វផ្សាយផ្ទាល់ ឬ ជាប្រយោល ដែលបំផ្លើសខុសការពិតទាំងអស់ ត្រូវហាមឃាត់ ។

**មាត្រា ១៩.-**

គ្រូពេទ្យត្រូវឃ្លាំមើលលើអ្វីដែលដាក់ឈ្មោះ គុណសម្បត្តិ ឬសេចក្តីប្រកាសរបស់ខ្លួនជានិច្ច ។ គ្រូពេទ្យមិនត្រូវអត់ឱនឱ្យជាដាច់ខាត ចំពោះអង្គការសាធារណៈ ឬឯកជនដែលខ្លួនធ្វើការជាមួយ ឬដែលខ្លួនសហការជាមួយ ប្រើប្រាស់នូវឈ្មោះ ឬសកម្មភាពវិជ្ជាជីវៈរបស់ខ្លួន ក្នុងទិសដៅឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម ។

**មាត្រា ២០.-**

លើកលែងតែមានបដិប្បញ្ញត្តិទទួលស្គាល់ក្នុងល័ក្ខខ័ណ្ឌណាមួយនៃច្បាប់ ការចែកចាយក្នុងគោលបំណងរកផលប្រយោជន៍ផ្ទាល់ខ្លួន របស់គ្រូពេទ្យនូវឱសថ ឧបករណ៍ ឬផលិតផលទាំងឡាយ ដែលហាក់បីដូចជាមានប្រយោជន៍ដល់សុខភាព ប៉ុន្តែពុំទាន់មានការធានាច្បាស់លាស់ ត្រូវហាមឃាត់ ។ គ្រូពេទ្យមិនត្រូវផ្តល់ឱសថ ដែលពុំបានទទួលការអនុញ្ញាតឱ្យប្រើដល់អ្នកជំងឺប្រើប្រាស់ឡើយ ។

**មាត្រា ២១.-**

ការបែងចែកតម្លៃនៃការព្យាបាលរវាងគ្រូពេទ្យ និងគ្រូពេទ្យ ទោះស្ថិតនៅក្រោមរូបភាពណាក៏ដោយ ត្រូវហាមឃាត់ លើកលែងតែក្នុងករណីដែលមានចែងក្នុងមាត្រា៩០ នៃអនុក្រឹត្យនេះ ។

ការព្រមទទួល ការទទូចទារ ឬ ការផ្តល់ភាគចំណែកតម្លៃនៃការព្យាបាល រវាងគ្រូពេទ្យពិតមែនតែមានហេតុផលក៏ដោយ ត្រូវហាមឃាត់ ។

**មាត្រា ២២.-**

ការរួមគំនិតគ្នាទាំងឡាយរវាងគ្រូពេទ្យ និងគ្រូពេទ្យ រវាងគ្រូពេទ្យ និងឱសថការី និងអ្នកជំនួយវេជ្ជសាស្ត្រ ឬ សាធារណជន ទាំងអស់ តាមផ្លូវកាយ ឬផ្លូវចិត្ត សម្រាប់ប្រយោជន៍បុគ្គល ត្រូវហាមឃាត់ ។

**មាត្រា ២៣.-**

គ្រូពេទ្យមិនត្រូវពិគ្រោះ ពិនិត្យ និងព្យាបាលអ្នកជំងឺនៅកន្លែងពាណិជ្ជកម្ម ឬនៅកន្លែងណាមួយផ្សេងទៀត ដែលមានដាក់លក់ឱសថ ផលិតផល ឧបករណ៍ពេទ្យដែលគ្រូពេទ្យនោះចេញវេជ្ជបញ្ជា ឬប្រើប្រាស់ ។

**មាត្រា ២៤.-**

គ្រូពេទ្យម្នាក់អាចប្រកបការងារមួយផ្សេងទៀតបាន លុះណាតែការងារនោះចុះសម្រុងនឹងឥស្សរភាព សេចក្តីថ្លៃថ្នូរវិជ្ជាជីវៈ និងមិនបណ្តាលឱ្យមានការទាញយកចំណេញ អំពីវេជ្ជបញ្ជា ឬការទូន្មានវេជ្ជសាស្ត្ររបស់គ្រូពេទ្យនោះ។

**មាត្រា ២៥.-**

គ្រូពេទ្យដែលកំពុងបំពេញអាណត្តិតាមរយៈការបោះឆ្នោត ឬ បំពេញមុខងារក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ មិនត្រូវប្រើប្រាស់តួនាទីទាំងនោះ ដើម្បីបង្កើនអតិថិជនរបស់ខ្លួនឡើយ ។

**មាត្រា ២៦.-**

ការផ្តល់របាយការណ៍លំអៀង ឬការផ្តល់វិញ្ញាបនបត្របន្លំ ដើម្បីតម្រូវចិត្តគ្នា ត្រូវហាមឃាត់ ។

**មាត្រា ២៧.-**

ការបន្លំ ការរំលោភទៅលើតម្លៃកំណត់ ការផ្តល់ព័ត៌មានមិនពិតអំពីតម្លៃនៃការព្យាបាលដែលបានទទួល និងអំពីទង្វើនានាដែលបានអនុវត្ត ត្រូវហាមឃាត់ ។

**មាត្រា ២៨.-**

ការជួយសម្រួលសព្វបែបយ៉ាងឱ្យអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រខុសច្បាប់ណាម្នាក់ ត្រូវហាមឃាត់ ។

**មាត្រា ២៩.-**

ទោះស្ថិតនៅក្រៅក្របខ័ណ្ឌនៃវិជ្ជាជីវៈក៏ដោយ គ្រូពេទ្យទាំងអស់ត្រូវតែជៀសវាងនូវអំពើទាំងឡាយ ដែលអាចធ្វើឱ្យអាប់អោនដល់វិជ្ជាជីវៈរបស់ខ្លួន ។

## ជំពូកទី ៣

## ករណីយកិច្ចរបស់គ្រូពេទ្យចំពោះអ្នកជំងឺ

**មាត្រា ៣០.-**

នៅពេលដែលព្រមទទួលពិនិត្យព្យាបាលអ្នកជំងឺ គ្រូពេទ្យត្រូវធ្វើការថែទាំដោយយកចិត្តទុកដាក់ ស្មោះត្រង់ ផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រ និងបើចាំបាច់ត្រូវរកជំនួយ ពីអ្នកដែលមានសមត្ថភាពខ្ពស់ជាង។

**មាត្រា ៣១.-**

គ្រូពេទ្យជានិច្ចកាលត្រូវធ្វើរោគវិនិច្ឆ័យយ៉ាងយកចិត្តទុកដាក់ ដោយចំណាយពេលវេលាដែលចាំបាច់ និងផ្អែកលើវិធីវិទ្យាសាស្ត្រស្របតាមតម្រូវការ ហើយបើចាំបាច់ត្រូវរកជំនួយសមស្រប ។

**មាត្រា ៣២.-**

គ្រូពេទ្យត្រូវសរសេរវេជ្ជបញ្ជា ឱ្យបានច្បាស់លាស់ ធ្វើយ៉ាងណាឱ្យអ្នកជំងឺ និងអ្នកជិតខាងបានយល់ និងអនុវត្តបានត្រឹមត្រូវ ។

**មាត្រា ៣៣.-**

ចំពោះអ្នកជំងឺដែលខ្លួនពិនិត្យព្យាបាល ឬឱ្យដំបូន្មាន គ្រូពេទ្យត្រូវបញ្ជាក់នូវព័ត៌មានដោយស្មោះត្រង់ ច្បាស់លាស់ និងសមស្រប អំពីស្ថានភាពរបស់អ្នកជំងឺ អំពីការស្រាវជ្រាវផ្សេងៗ និងការថែទាំដែលគ្រូពេទ្យត្រូវធ្វើក្នុងរយៈពេលនៃការព្យាបាល ។

គ្រូពេទ្យត្រូវគិតគូរដល់បុគ្គលិកលក្ខណៈ របស់អ្នកជំងឺទាំងនេះក្នុងការពន្យល់ និងធ្វើយ៉ាងណាឱ្យគេបានយល់ ។

ប៉ុន្តែ ក្នុងផលប្រយោជន៍របស់អ្នកជំងឺ និងដោយមូលហេតុសីលធម៌ក្នុងសម្បជញ្ញៈរបស់គ្រូពេទ្យ អ្នកជំងឺអាចមិនគួរដឹងអំពីរោគវិនិច្ឆ័យ ឬ អំពីបុរេនិមិត្តធ្ងន់ធ្ងរណាមួយ លើកលែងតែក្នុងករណីដែលជំងឺនោះ អាចឆ្លងដល់អ្នកជិតខាង ។

ការផ្តល់ព័ត៌មានបុរេនិមិត្តអស់សង្ឃឹមដល់អ្នកជំងឺ ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ។ គ្រួសាររបស់អ្នកជំងឺត្រូវតែបានទទួលដំណឹងនេះ លើកលែងតែជនណាដែលអ្នកជំងឺបានហាម ។

**មាត្រា ៣៤.-**

នៅគ្រប់ករណីទាំងអស់ ការពិនិត្យ ឬការថែទាំ ត្រូវតែបានទទួលការយល់ព្រមពីសាមីអ្នកជំងឺ ។

កាលណាអ្នកជំងឺ ដែលបានស្មារតីធម្មតា បដិសេធការអនុវត្តការស្រាវជ្រាវ ឬវិធីព្យាបាលដែលបម្រុងធ្វើទៅលើខ្លួនគេ គ្រូពេទ្យត្រូវតែគោរពតាម ក្រោយពីបានពន្យល់អ្នកជំងឺឱ្យបានដឹង អំពីផលវិបាកនៃការបដិសេធនោះ ។

បើអ្នកជំងឺមិនអាចសម្តែងឆន្ទៈរបស់ខ្លួនបាន គ្រូពេទ្យមិនអាចធ្វើអន្តរាគមន៍បានឡើយ បើពុំមានវត្តមានរបស់គ្រួសារអ្នកជំងឺនៅជាមួយ លើកលែងតែក្នុងករណីបន្ទាន់ ឬមិនអាចធ្វើការទាក់ទងនឹងគ្រួសារនោះបាន ។

**មាត្រា ៣៥.-**

គ្រូពេទ្យទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ត្រូវខិតខំជួយសម្រាលដល់ការទុក្ខព្រួយរបស់អ្នកជំងឺ ជួយគាំពារខាងផ្លូវចិត្ត និងជៀសវាងនូវគំនិតមានះគ្មានហេតុផល ក្នុងការវិភាគស្រាវជ្រាវ ឬក្នុងការព្យាបាល ។

**មាត្រា ៣៦.-**

គ្រូពេទ្យត្រូវស្ថិតនៅជិតអ្នកដែលហៀបនឹងស្លាប់ រហូតដល់ដង្ហើមចុងក្រោយ បន្តធ្វើការថែទាំ និងចាត់វិធានការសមស្របទៅនឹងគុណសម្បត្តិ នៃជីវិតមួយដែលនឹងត្រូវផុតរលត់ រក្សាសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺ និងផ្តល់កម្លាំងចិត្តដល់អ្នកនៅជុំវិញ ។

គ្រូពេទ្យគ្មានសិទ្ធិបង្កឱ្យមនុស្សស្លាប់ ដោយចេតនាឡើយ ។

**មាត្រា ៣៧.-**

គ្រូពេទ្យមិនអាចផ្តល់ឱ្យអ្នកជំងឺ ឬអ្នកនៅជុំវិញនូវឱសថ ឬរបៀបព្យាបាលដែលមានលក្ខណៈមិនច្បាស់លាស់ ឬ មិនទាន់ត្រូវបានពិសោធន៍គ្រប់គ្រាន់ ទោះបីយល់ឃើញថា វាអាចជួយទ្រទ្រង់សុខភាព ឬពុំមានគ្រោះថ្នាក់ក៏ដោយ ។

ការព្យាបាលតាមរបៀបបោកប្រាស់ ត្រូវហាមឃាត់ ។

**មាត្រា ៣៨.-**

គ្រូពេទ្យមិនត្រូវបង្កគ្រោះថ្នាក់ដោយគ្មានហេតុផលដល់អ្នកជំងឺ នៅក្នុងការស្រាវជ្រាវជំងឺ និងអន្តរាគមន៍ផ្សេងៗ ក៏ដូចជានៅក្នុងការព្យាបាល ។

**មាត្រា ៣៩.-**

បើពុំមានមូលហេតុវេជ្ជសាស្ត្រធ្ងន់ធ្ងរ និងពុំបានឱ្យអ្នកជំងឺដឹង និងយល់ព្រមជាមុនទេ ការវះកាត់មិនត្រូវបន្សល់ទុកនូវពិការភាព លើកលែងតែមានការបន្ទាន់បំផុត ឬមិនអាចធ្វើការទាក់ទងនឹងគ្រួសាររបស់អ្នកជំងឺ ។

**មាត្រា ៤០.-**

គ្រូពេទ្យដែលអញ្ជើញឱ្យផ្តល់ការថែទាំព្យាបាលដល់អនីតិជន ឬអសមត្ថជនពេញវ័យ ត្រូវខិតខំជូនព័ត៌មានដល់ឪពុកម្តាយ ឬអ្នកតំណាងតាមផ្លូវច្បាប់របស់សាមីជន និងទទួលការយល់ព្រមអំពីអ្នកទាំងនោះ ។

ក្នុងករណីបន្ទាន់ ទោះបីមិនអាចធ្វើការទាក់ទងនឹងអ្នកទាំងនោះបានក៏ដោយ ក៏គ្រូពេទ្យត្រូវតែធ្វើការថែទាំព្យាបាលដែលចាំបាច់ ។

ប្រសិនណាជាសាមីជនអាចបញ្ចេញមតិបាន គ្រូពេទ្យត្រូវគិតគូរដល់មតិនេះ បើអាចធ្វើទៅបាន ។

**មាត្រា ៤១.-**

គ្រូពេទ្យត្រូវជាអ្នកការពាររបស់កុមារ នៅពេលណាគ្រូពេទ្យយល់ឃើញថា អ្នកនៅជុំវិញកុមារនោះមិនបានយល់ និងមិនបានការពារផលប្រយោជន៍នៃសុខភាពរបស់កុមារ ។

**មាត្រា ៤២.-**

គ្រូពេទ្យនៅពេលដែលបានដឹងថា អ្នកជំងឺដែលមកព្យាបាលបានទទួលរងគ្រោះដោយការធ្វើទុក្ខទោស ឬ បង្អត់អាហារ គ្រូពេទ្យត្រូវប្រើគ្រប់មធ្យោបាយសមស្រប ដើម្បីការពារសាមីជនដោយប្រុងប្រយ័ត្ន ។

បើអ្នកជំងឺជាកុមារក្រោមអាយុ ១៥ឆ្នាំ ឬជាជនដែលមិនអាចការពារខ្លួនបានដោយមូលហេតុ អាយុ សុភាពរាងកាយ ឬសតិអារម្មណ៍ គ្រូពេទ្យត្រូវផ្តល់ដំណឹងជាបន្ទាន់ទៅអាជ្ញាធរតុលាការ សុខាភិបាល ឬ រដ្ឋបាល លើកលែងតែករណីសំងាត់ទេសៈពិសេសដែលគ្រូពេទ្យយល់ថាគួរធ្វើ ។

**មាត្រា ៤៣.-**

គ្រូពេទ្យត្រូវធ្វើសលាកបត្រកត់ត្រាមួយសម្រាប់អ្នកជំងឺម្នាក់ ។ សលាកប័ត្រនេះ ត្រូវរក្សាជាការសម្ងាត់សម្រាប់កត់ត្រាព័ត៌មានប្រចាំថ្ងៃ ដែលជាប្រយោជន៍ចាំបាច់ក្នុងការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល ។

ក្នុងគ្រប់ករណីទាំងអស់ គ្រូពេទ្យទទួលខុសត្រូវថែរក្សាឯកសារទាំងនេះ ។

តាមសំណូមពរ ឬដោយមានការយល់ព្រមពីអ្នកជំងឺ គ្រូពេទ្យត្រូវបញ្ជូនព័ត៌មាន និងឯកសារចាំបាច់ផ្សេងៗសម្រាប់បន្តការព្យាបាល ទៅគ្រូពេទ្យដែលចូលរួមព្យាបាល ឬ គ្រូពេទ្យដែលអ្នកជំងឺសម្រេចចិត្តទៅពិគ្រោះបន្ត ។

**មាត្រា ៤៤.-**

- ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ និរន្តរភាពនៃការថែទាំអ្នកជំងឺ ត្រូវបានធានា ។

ក្រៅពីករណីបន្ទាន់ និងក្នុងករណីដែលគ្រូពេទ្យមិនអាចបំពេញករណីយកិច្ចមនុស្សធម៌របស់ខ្លួនបាន គ្រូពេទ្យមានសិទ្ធិបដិសេធការថែទាំបាន ដោយមូលហេតុវិជ្ជាជីវៈ ឬផ្ទាល់ខ្លួន ។

បើសិនជាគ្រូពេទ្យបដិសេធបេសកកម្មនេះ គ្រូពេទ្យត្រូវផ្តល់ដំណឹងដល់អ្នកជំងឺ និងត្រូវបញ្ជូនទៅគ្រូពេទ្យដែលអ្នកជំងឺជ្រើសរើស នូវព័ត៌មានចាំបាច់ដើម្បីធ្វើការថែទាំបន្ត ។

**មាត្រា ៤៥.-**

គ្រូពេទ្យមិនអាចបោះបង់អ្នកជំងឺរបស់ខ្លួន នៅពេលមានគ្រោះថ្នាក់សាធារណៈ លើកលែងតែបានទទួលបញ្ជាដាច់ខាត ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមល័ក្ខខ័ណ្ឌច្បាប់ ។

**មាត្រា ៤៦.-**

គ្រូពេទ្យដែលអញ្ជើញឱ្យធ្វើការថែទាំនៅក្នុងគ្រួសារ ឬ ក្នុងសមូហភាព ត្រូវខិតខំធ្វើយ៉ាងណាឱ្យមានការគោរពវិធានការអនាម័យ និង វិធីបង្ការរោគ ។

គ្រូពេទ្យត្រូវប្រាប់អ្នកជំងឺអំពីការទទួលខុសត្រូវ និងករណីយកិច្ចរបស់អ្នកជំងឺចំពោះខ្លួនឯង និងចំពោះអ្នកដទៃ ព្រមទាំងអំពីការប្រុងប្រយ័ត្ននានា ដែលអ្នកជំងឺត្រូវយកចិត្តទុកដាក់ ។

**មាត្រា ៤៧.-**

គ្រូពេទ្យត្រូវជួយសម្រួលអ្នកជំងឺ ក្នុងការបានទទួលផលប្រយោជន៍សង្គមទាំងឡាយ ដែលអ្នកជំងឺត្រូវបានទទួលតាមផ្លូវច្បាប់ ដោយមិនយោគយល់តាមការចង់បានហួសហេតុរបស់អ្នកជំងឺ ។

អាស្រ័យហេតុនេះ លើកលែងតែមានការជំទាស់ពីអ្នកជំងឺ គ្រូពេទ្យត្រូវបានអនុញ្ញាតឱ្យផ្តល់ព័ត៌មានវេជ្ជសាស្ត្រដែលចាំបាច់ទៅ គ្រូពេទ្យទីប្រឹក្សារបស់អង្គការនិរភ័យសង្គមដែលអ្នកជំងឺចំណុះ ឬទៅគ្រូពេទ្យនៃអង្គការសាធារណៈ ដែលមានសិទ្ធិសម្រេចបែងចែកផលប្រយោជន៍សង្គម ។

**មាត្រា ៤៨.-**

គ្រូពេទ្យមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការគ្រួសារ ឬក្នុងជីវភាពផ្ទាល់ខ្លួនរបស់អ្នកជំងឺឡើយ បើពុំមានមូលហេតុវិជ្ជាជីវៈ ។

**មាត្រា ៤៩.-**

គ្រូពេទ្យដែលបានព្យាបាលអ្នកជំងឺម្នាក់ រហូតដល់អ្នកជំងឺនោះទទួលមរណៈភាព នឹងអាចទទួលផលប្រយោជន៍បានតាមការសម្តែងចេញ ឬតាមសំបុត្របណ្តាំរបស់អ្នកស្លាប់ ដែលបានធ្វើក្នុងពេលកំពុងព្យាបាល តែក្នុងករណី និងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ ។

- គ្រូពេទ្យមិនត្រូវលោភលន់ដោយប្រើឥទ្ធិពល ដើម្បីបានទទួលអំណាច ឬការចុះកិច្ចសន្យាណាមួយដែលជាល័ក្ខខ័ណ្ឌមានអំណោយផលមិនធម្មតា ដល់គ្រូពេទ្យនោះ ។

**មាត្រា ៥០.-**

តម្លៃនៃការព្យាបាលរបស់គ្រូពេទ្យត្រូវតែកំណត់តាមខ្នាតមាត្រា ដោយផ្អែកទៅលើសកម្មភាពដែលបានអនុវត្ត ឬក្នុងកាលៈទេសៈពិសេស ។ តម្លៃនៃការព្យាបាលទាំងនេះនឹងអាចទាមទារបាន តែក្រោយពេលអនុវត្តការងារ ។

គ្រូពេទ្យមិនត្រូវទាមទារតម្លៃនៃការព្យាបាល ចំពោះការពន្យល់ ឬផ្តល់ដំបូន្មានទៅអ្នកជំងឺតាមទូរសព្ទ័ ឬតាមលិខិតស្នាមឡើយ ។

គ្រូពេទ្យត្រូវឆ្លើយតបរាល់ការសុំព័ត៌មាន និងការពន្យល់អំពីតម្លៃនៃការព្យាបាល ។

ពុំមានវិធីបង់ប្រាក់ពិសេសណាមួយ អាចត្រូវបង្ខំទៅលើអ្នកជំងឺឡើយ ។

**មាត្រា ៥១.-**

កាលណាគ្រូពេទ្យច្រើននាក់សហការគ្នាពិនិត្យ ឬព្យាបាល តម្លៃនៃការព្យាបាលត្រូវធ្វើឡើងចំពោះគ្រូពេទ្យម្នាក់ៗដាច់ដោយឡែកពីគ្នា។

ការឧបត្ថម្ភចំពោះអ្នកជំនួយការដែលជ្រើសរើស និងធ្វើការក្រោមការត្រួតពិនិត្យរបស់គ្រូពេទ្យណា ត្រូវតែបញ្ចូលទៅលើកំណត់តម្លៃនៃការព្យាបាលរបស់គ្រូពេទ្យនោះ ។

**មាត្រា ៥២.-**

- នៅគ្រប់កាលៈទេសៈ ការសន្យាម៉ៅការដើម្បីប្រសិទ្ធភាពនៃការព្យាបាលព្រមទាំងការទាមទារប្រាក់កក់ ត្រូវហាមឃាត់ ។

## ជំពូកទី ៤

## ទំនាក់ទំនងរវាងគ្រូពេទ្យ និងគ្រូពេទ្យ និងជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងៗ

**មាត្រា ៥៣.-**

គ្រូពេទ្យត្រូវថែរក្សាទំនាក់ទំនងជាសហភាតរៈល្អ រវាងគ្នានិងគ្នា ។

គ្រូពេទ្យដែលមានទំនាស់ជាមួយគ្នាត្រូវស្វែងរកដំណោះស្រាយតាមការផ្សះផ្សា ហើយបើចាំបាច់ត្រូវធ្វើតាមរយៈក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។

គ្រូពេទ្យត្រូវចេះជួយគ្នាទៅវិញទៅមកក្នុងពេលមានទុក្ខលំបាក ។

**មាត្រា ៥៤.-**

ការពង្វាង ឬការប៉ុនប៉ងពង្វាងអតិថិជន ត្រូវហាមឃាត់ ។

**មាត្រា ៥៥.-**

គ្រូពេទ្យ នៅពេលបានទទួលពិគ្រោះអ្នកជំងឺដែលសហភាតរៈម្នាក់ទៀតបានព្យាបាលមុន ត្រូវ :

- គោរពផលប្រយោជន៍របស់អ្នកជំងឺ ដោយធ្វើការព្យាបាលពិសេសតែលើស្ថានភាពបន្ទាន់
- គោរពសិទ្ធិជ្រើសរើសរបស់អ្នកជំងឺ ដែលមានបំណងរកគ្រូពេទ្យផ្សេង ។

ដោយមានការយល់ព្រមពីអ្នកជំងឺ គ្រូពេទ្យពិគ្រោះត្រូវផ្តល់ព័ត៌មានទៅគ្រូពេទ្យព្យាបាលនូវការសង្កេតឃើញ និងការសម្រេចចិត្តផ្សេងៗ ។ ក្នុងករណីមានការបដិសេធពីអ្នកជំងឺ គ្រូពេទ្យពិគ្រោះត្រូវប្រាប់អ្នកជំងឺអំពីផលវិបាកទាំងឡាយដែលអាចកើតមានឡើងពីការបដិសេធនោះ ។

**មាត្រា ៥៦.-**

គ្រូពេទ្យ នៅពេលអញ្ជើញឱ្យពិគ្រោះអ្នកជំងឺម្នាក់ជាបន្ទាន់ បើសិនជាអ្នកជំងឺនោះត្រូវទទួលការពិនិត្យជាថ្មីដោយគ្រូពេទ្យព្យាបាលរបស់គេ ឬដោយគ្រូពេទ្យម្នាក់ផ្សេងទៀត គ្រូពេទ្យពិគ្រោះបន្ទាន់នោះត្រូវសរសេររបាយការណ៍អំពីអន្តរាគមន៍ និងការព្យាបាលរបស់ខ្លួនប្រគល់ឱ្យអ្នកជំងឺ ឬផ្ញើទៅសហភាតរៈដោយផ្ទាល់ ក្រោយពីប្រាប់អ្នកជំងឺ ឱ្យបានដឹង ។

គ្រូពេទ្យពិគ្រោះត្រូវរក្សាទុកឯកសារចម្លងមួយច្បាប់ ។

**មាត្រា ៥៧.-**

គ្រូពេទ្យ ក្នុងកាលៈទេសៈចាំបាច់ ត្រូវស្នើការពិគ្រោះយោបល់ជាមួយសហភាតរៈណាម្នាក់ ឬទទួលពិគ្រោះជាមួយគ្រូពេទ្យ ដែលស្នើឡើងដោយអ្នកជំងឺ ឬដោយអ្នកនៅជុំវិញអ្នកជំងឺ ។

បើសិនជាគ្រូពេទ្យពិគ្រោះយល់ឃើញថា មិនអាចទទួលយល់ព្រមតាមការជ្រើសរើសរបស់អ្នកជំងឺ គ្រូពេទ្យពិគ្រោះអាចបដិសេធ មិនចូលរួមបាន ។ គ្រូពេទ្យពិគ្រោះអាចជូនយោបល់ឱ្យអញ្ជើញគ្រូពេទ្យផ្សេងណាមួយ តាមដែលគ្រូពេទ្យនោះបានគិតកាលបើមិនមាន ការជ្រើសរើសរបស់អ្នកជំងឺ ។

ក្រោយពីការពិគ្រោះ គ្រូពេទ្យនោះត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដល់គ្រូពេទ្យព្យាបាលអំពីការសង្កេតឃើញ ការសន្និដ្ឋាន និងការព្យាបាលជាយថាហេតុរបស់ខ្លួន ដោយប្រាប់អ្នកជំងឺឱ្យបានដឹង ។

**មាត្រា ៥៨.-**

ក្រោយពីការពិគ្រោះ កាលណាគ្រូពេទ្យពិគ្រោះ និងគ្រូពេទ្យព្យាបាលមានមតិខុសគ្នាខ្លាំង អ្នកជំងឺត្រូវតែបានដឹងអំពីបញ្ហានេះ ។ គ្រូពេទ្យព្យាបាល មានសិទ្ធិផ្អាកការថែទាំរបស់ខ្លួន បើសិនជាអ្នកជំងឺ ឬ អ្នកនៅជុំវិញមានជំនឿទុកចិត្តលើគ្រូពេទ្យពិគ្រោះ ។

**មាត្រា ៥៩.-**

គ្រូពេទ្យពិគ្រោះមិនត្រូវផ្តួចផ្តើមអញ្ជើញ ឬពិនិត្យអ្នកជំងឺសារជាថ្មី ដោយមិនបានជម្រាបគ្រូពេទ្យព្យាបាលឱ្យបានដឹងជាមុន លើកលែងតែមានភាពបន្ទាន់ ។

គ្រូពេទ្យពិគ្រោះយោបល់ មិនត្រូវបន្តការថែទាំដោយផ្អែកទៅលើស្ថានភាព របស់អ្នកជំងឺទៀតទេ នៅពេលការថែទាំនេះ គឺជាសមត្ថកិច្ចរបស់គ្រូពេទ្យព្យាបាល លើកលែងតែជាឆន្ទៈរបស់អ្នកជំងឺ ហើយគ្រូពេទ្យពិគ្រោះត្រូវផ្តល់ព័ត៌មានចាំបាច់ទាំងអស់ដល់គ្រូពេទ្យព្យាបាលសំរាប់តាមដានអ្នកជំងឺ ។

**មាត្រា ៦០.-**

ដោយមិនបំពានដល់បទប្បញ្ញត្តិ ស្តីពីសេវាព្យាបាលរបស់មន្ទីរពេទ្យសាធារណៈ និងឯកជន គ្រូពេទ្យទទួលបន្ទុកព្យាបាលអ្នកជំងឺ ដែលចូលក្នុងមន្ទីរពេទ្យត្រូវផ្តល់ព័ត៌មានអំពីការសម្រាកពេទ្យនេះដល់គ្រូពេទ្យព្យាបាល ឬអ្នកជិតខាងដែលអ្នកជំងឺបានប្រាប់ ។ គ្រូពេទ្យនៃមន្ទីរពេទ្យនោះត្រូវផ្តល់ព័ត៌មានដល់គ្រូពេទ្យព្យាបាលអំពីសេចក្តីសម្រេចចាំបាច់ទាំងឡាយ ដែលគ្រូពេទ្យព្យាបាលនោះអាចត្រូវអញ្ជើញឱ្យចូលរួម បើអាចធ្វើទៅបាន ។

**មាត្រា ៦១.-**

នៅពេលណាគ្រូពេទ្យច្រើននាក់សហការគ្នាពិនិត្យ ឬព្យាបាលអ្នកជំងឺម្នាក់ គ្រូពេទ្យទាំងនោះត្រូវផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។ គ្រូពេទ្យម្នាក់ៗទទួលខុសត្រូវរៀងៗខ្លួន និងតាមឃ្លាំមើលការវិវត្តនៃអ្នកជំងឺជានិច្ច ។

គ្រូពេទ្យម្នាក់ៗអាចបដិសេធមិនចូលរួម ឬបញ្ឈប់ការសហការរបស់ខ្លួនបាន តែក្នុងល័ក្ខខ័ណ្ឌដែលការមិនចូលរួម ឬការបញ្ឈប់នេះ មិនបង្កភាពអន្តរាយដល់អ្នកជំងឺ ហើយត្រូវផ្តល់ដំណឹងឱ្យដល់សហភាគរៈទាំងអស់ ។

**មាត្រា ៦២.-**

គ្រូពេទ្យម្នាក់អាចឱ្យសហភាគរៈម្នាក់ ឬ និស្សិតអន្តេវាសិកវេជ្ជសាស្ត្រម្នាក់ ដែលបានបំពេញល័ក្ខខ័ណ្ឌកំណត់ដោយគណៈគ្រូពេទ្យជំនួស ក្នុងមុខរបរវិជ្ជាជីវៈជាបណ្តោះអាសន្នបាន ។ គ្រូពេទ្យនោះត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុងពាក់ព័ន្ធជាមុនអំពី ឈ្មោះ គុណវុឌ្ឍិរបស់អ្នកចូលជំនួស ព្រមទាំងថ្ងៃ ខែ និង រយៈពេលនៃការជំនួស ។

គ្រូពេទ្យដែលត្រូវគេជំនួស ត្រូវបញ្ឈប់សកម្មភាពវេជ្ជសាស្ត្រសេរីទាំងអស់នៅក្នុងរយៈពេលនៃការជំនួស ។

**មាត្រា ៦៣.-**

នៅពេលបញ្ចប់ការជំនួស អ្នកជំនួសត្រូវបញ្ឈប់សកម្មភាពទាក់ទង នឹងការជំនួសទាំងអស់ និងប្រគល់ព័ត៌មានចាំបាច់ផ្សេងៗដល់គ្រូពេទ្យសាមី ដើម្បីនិរន្តរភាពនៃការថែទាំ ។

**មាត្រា ៦៤.-**

ការអនុវត្តទាំងឡាយដែលមាននិន្នាការបញ្ចុះតំលៃ នៃការព្យាបាលរបស់គ្រូពេទ្យ ក្នុងគោលបំណងប្រកួតប្រជែង ត្រូវហាមឃាត់ ។

គ្រូពេទ្យមានសេរីភាពក្នុងការផ្តល់ការថែទាំ ដោយមិនយកថ្លៃព្យាបាល ។

**មាត្រា ៦៥.-**

ដើម្បីផលប្រយោជន៍របស់អ្នកជំងឺ គ្រូពេទ្យត្រូវរក្សាទំនាក់ទំនងល្អ ជាមួយសមាជិកទាំងឡាយ នៃវិជ្ជាជីវៈសុខាភិបាល ។ សមាជិកទាំងនោះត្រូវគោរពឯករាជ្យភាពវិជ្ជាជីវៈទៅវិញទៅមក និងគោរពសេរីភាពក្នុងការជ្រើសរើសរបស់អ្នកជំងឺ ។

## ជំពូកទី ៥

## អំពីការប្រកបវិជ្ជាជីវៈ

### ផ្នែកទី ១

### គោលការណ៍រួមនៃគ្រប់សណ្ឋានវិជ្ជាជីវៈ

**មាត្រា ៦៦.-**

ការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ គឺជាការងារផ្ទាល់របស់គ្រូពេទ្យម្នាក់ៗ ។ គ្រូពេទ្យម្នាក់ៗទទួលខុសត្រូវ ចំពោះសេចក្តីសម្រេច និងអំពើទាំងឡាយរបស់ខ្លួន ។

**មាត្រា ៦៧.-**

ជាគោលការណ៍ គ្រូពេទ្យទាំងអស់មាននីតិសម្បទា ក្នុងការធ្វើរោគវិនិច្ឆ័យ ធ្វើវិធីបង្ការ និងធ្វើការព្យាបាល ។ លើកលែងតែក្នុងកាលៈទេសៈពិសេស ក្នុងវិស័យណាដែលហួសសមត្ថភាព បទពិសោធន៍ និងមធ្យោបាយដែលមាន គ្រូពេទ្យមិនត្រូវផ្តើមធ្វើ ឬបន្តការថែទាំ ឬសរសេរវេជ្ជបញ្ជាផ្សេងៗឡើយ ។

**មាត្រា ៦៨.-**

នៅកន្លែងប្រកបវិជ្ជាជីវៈ គ្រូពេទ្យត្រូវមានទីតាំងធ្វើការសមរម្យ មានបន្ទប់ត្រឹមត្រូវ អាចរក្សាការសម្ងាត់វិជ្ជាជីវៈបាន និង មធ្យោបាយបច្ចេកទេសគ្រប់គ្រាន់ សមស្របទៅនឹងប្រភេទកិច្ចការដែលគ្រូពេទ្យត្រូវធ្វើ ឬស្របទៅនឹងប្រជាពលរដ្ឋដែលគ្រូពេទ្យទទួលខុសត្រូវ ។ គ្រូពេទ្យត្រូវប្រុងប្រយ័ត្នជាពិសេសទៅលើការរំងាប់មេរោគ និងការកាត់ផ្តាច់ការចម្លងមេរោគនៃឧបករណ៍ សម្ភារៈពេទ្យដែលប្រើប្រាស់ ព្រមទាំងការបំបាត់កាកសំណល់វេជ្ជសាស្ត្រ តាមនីតិវិធីនៃបទបញ្ជា ។

គ្រូពេទ្យមិនត្រូវប្រកបវិជ្ជាជីវៈនៅក្នុងល័ក្ខខ័ណ្ឌដែលអាចធ្វើឱ្យខូចគុណភាពនៃការថែទាំ និងសកម្មភាពវេជ្ជសាស្ត្រ ឬធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរបស់អ្នកជំងឺ ។

គ្រូពេទ្យត្រូវត្រួតពិនិត្យសមត្ថភាពអ្នក ដែលបានចូលរួមការងារជាមួយ ។

**មាត្រា ៦៩.-**

គ្រូពេទ្យត្រូវធ្វើយ៉ាងណាឱ្យអ្នកជំនួយការរបស់ខ្លួន បានចេះដឹងអំពីកាតព្វកិច្ចទាំងអស់គ្នា ក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ និងឱ្យគោរពតាម ។

គ្រូពេទ្យត្រូវប្រុងប្រយ័ត្នកុំឱ្យអ្នកនៅជុំវិញខ្លួន ធ្វើឱ្យលេចពុការសម្ងាត់ តាមរយៈលិខិតឆ្លើយឆ្លងវិជ្ជាជីវៈ ។

**មាត្រា ៧០.-**

គ្រូពេទ្យត្រូវការពារការទំលាយអាថិកំបាំងនៃឯកសារ និងព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកជំងឺ ដែលគ្រូពេទ្យបានថែទាំ ឬពិនិត្យ ព្យាបាល ទោះបីជាឯកសារទាំងនោះមានអត្ថន័យ និងអត្ថប្រយោជន៍យ៉ាងណាក៏ដោយក្តី ។

- គ្រូពេទ្យនៅពេលដែលត្រូវប្រើប្រាស់បទពិសោធន៍ ឬ ឯកសាររបស់ខ្លួនក្នុងគោលបំណងផ្សព្វផ្សាយវិទ្យាសាស្ត្រ ឬបង្ហាត់បង្រៀន ត្រូវធ្វើយ៉ាងណាកុំឱ្យអត្តសញ្ញាណរបស់អ្នកជំងឺត្រូវបានឱ្យដឹង បើមិនដូច្នេះទេត្រូវសុំការអនុញ្ញាតពីសាមីអ្នកជំងឺ ។

**មាត្រា ៧១.-**

គ្រូពេទ្យមិនត្រូវប្រើរហស្សនាម ដើម្បីប្រកបមុខរបរវេជ្ជសាស្ត្រ លើកលែងតែបានទទួលការយល់ព្រមពីក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។

**មាត្រា ៧២.-**

ការចេញវិញ្ញាបនបត្រពេទ្យ សំបុត្របញ្ជាក់ និង ឯកសារផ្សេងៗ ត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ជា ។

វិញ្ញាបនបត្រ វេជ្ជបញ្ជា សំបុត្របញ្ជាក់ ឬ ឯកសារទាំងអស់ដែលចេញដោយគ្រូពេទ្យ ត្រូវសរសេរឱ្យបានច្បាស់លាស់ ងាយអាន ជាភាសាជាតិ ដោយមានថ្ងៃ-ខែ-ឆ្នាំ និងចុះហត្ថលេខារបស់គ្រូពេទ្យ ។ គ្រូពេទ្យអាចប្រគល់ឱ្យអ្នកជំងឺនូវឯកសារបកប្រែជាភាសាជាតិរបស់អ្នកជំងឺ ។

**មាត្រា ៧៣.-**

ក្នុងក្របខ័ណ្ឌធានានិរន្តរភាពនៃការថែទាំ គ្រូពេទ្យមានករណីកិច្ចចូលរួមយាមកាមនៅពេលថ្ងៃ និងពេលយប់ ។ ប៉ុន្តែក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង អាចអធ្យាស្រ័យបានដោយថាហេតុ ដោយយោលទៅតាមអាយុ សុខភាព និងល័ក្ខខ័ណ្ឌប្រកបមុខរបររបស់គ្រូពេទ្យ ។

**មាត្រា ៧៤.-**

កាលណាគ្រូពេទ្យត្រូវចូលរួមនៅក្នុងសេវាយាមកាម សេវាសង្គ្រោះបន្ទាន់ ឬតម្រូវឱ្យបំពេញកាតព្វកិច្ចអ្វីមួយ គ្រូពេទ្យត្រូវធ្វើយ៉ាងណាឱ្យបានទៅដល់កន្លែង យ៉ាងឆាប់បំផុត ។

ដើម្បីសំរួលដល់បេសកកម្មនេះ គ្រូពេទ្យត្រូវបានអនុញ្ញាតឱ្យបិទផ្លាក " គ្រូពេទ្យសង្គ្រោះបន្ទាន់ " នៅលើកញ្ចក់មុខរថយន្ត ហើយត្រូវបកផ្លាកនេះចេញវិញ នៅពេលដែលការចូលរួមសង្គ្រោះបន្ទាន់ ត្រូវបានបញ្ចប់ ។

គ្រូពេទ្យសង្គ្រោះត្រូវផ្តល់ព័ត៌មាន ដល់គ្រូពេទ្យព្យាបាលរបស់អ្នកជំងឺ អំពីអន្តរាគមន៍របស់ខ្លួន ស្របតាមល័ក្ខខ័ណ្ឌ

ដែលមានចែងនៅក្នុងមាត្រា៥៦ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧៥.-**

ការបញ្ជាក់មួយចំនួនដែលគ្រូពេទ្យ ត្រូវបានអនុញ្ញាត ឱ្យដាក់នៅលើក្រដាសវេជ្ជបញ្ជា មាន ÷

១. នាមត្រកូល នាមខ្លួន អាសយដ្ឋានវិជ្ជាជីវៈ លេខទូរស័ព្ទ និង ទូរសារ ថ្ងៃ និង ម៉ោងទទួលពិគ្រោះ ។

២. បើគ្រូពេទ្យប្រកបមុខរបរជាក្រុម ត្រូវដាក់ឈ្មោះគ្រូពេទ្យទាំងអស់ក្នុងក្រុមនោះ ។

៣. ស្ថានភាពរបស់គ្រូពេទ្យចំពោះអង្គការធានារ៉ាប់រងជំងឺ បើសិនជាមាន ។

៤. គុណវុឌ្ឍិទទួលស្គាល់ដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងគណៈគ្រូពេទ្យ ដែលមានការយល់ព្រម ពីក្រសួងសុខាភិបាល ។

**មាត្រា ៧៦.-**

ការបញ្ជាក់មួយចំនួនដែលគ្រូពេទ្យ ត្រូវបានអនុញ្ញាត ឱ្យចុះនៅក្នុងសៀវភៅផ្សាយសម្រាប់សាធារណៈ គឺ ÷

១. នាមត្រកូល នាមខ្លួន អាសយដ្ឋានវិជ្ជាជីវៈ លេខទូរស័ព្ទ និង ទូរសារ ថ្ងៃ និង ម៉ោងទទួលពិគ្រោះ ។

២. ស្ថានភាពរបស់គ្រូពេទ្យចំពោះអង្គការធានារ៉ាប់រងជំងឺ បើមាន ។

៣. គុណវុឌ្ឍិ សញ្ញាប័ត្រសិក្សាឯកទេស និងសមត្ថភាពផ្សេងៗ ទទួលស្គាល់ដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងគណៈគ្រូពេទ្យ ដែលមានការយល់ព្រមពីក្រសួងសុខាភិបាល ។

**មាត្រា ៧៧.-**

ការបញ្ជាក់មួយចំនួនដែលគ្រូពេទ្យ ត្រូវបានអនុញ្ញាតឱ្យសរសេរនៅលើផ្លាកកន្លែងធ្វើការ មាន ÷

នាមត្រកូល នាមខ្លួន លេខទូរស័ព្ទ ថ្ងៃ និងម៉ោងទទួលពិគ្រោះ ស្ថានភាពផ្ទាល់ខ្លួនចំពោះអង្គការទទួលរ៉ាប់រងជំងឺ សញ្ញាប័ត្រ មុខងារ និងគុណវុឌ្ឍិដែលទទួលស្គាល់ ដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងគណៈគ្រូពេទ្យ ដែលមានការយល់ព្រមពីក្រសួងសុខាភិបាល ។

ផ្លាកមួយនេះអាចដាក់នៅមុខទ្វារចូលអាគារ និងមួយទៀតនៅមាត់ទ្វារបន្ទប់ពិគ្រោះជំងឺ ក្នុងភាពសមរម្យសម្រាប់វិជ្ជាជីវៈ ។

**មាត្រា ៧៨.-**

នៅពេលបើកទីតាំងថ្មី ឬមានការផ្លាស់ប្តូរមុខជំនាញ គ្រូពេទ្យអាចផ្សាយដំណឹងតាមសារព័ត៌មានបាន ដោយពុំមានលក្ខណៈជាការឃោសនា ។ អត្ថបទ និងរបៀបផ្សាយត្រូវផ្ញើទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ឱ្យបានដឹងជាមុន ។

**មាត្រា ៧៩.-**

ការប្រកបមុខរបរវេជ្ជសាស្ត្រ ទោះស្ថិតនៅក្រោមរូបភាពណាក៏ដោយ នៅក្នុងសហគ្រាស នៅក្នុងសមូហភាព ឬនៅក្នុងស្ថាប័ន ដែលជាសមត្ថកិច្ចនៃច្បាប់ឯកជន ត្រូវតែធ្វើឡើងក្រោមកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ។

កិច្ចសន្យានោះត្រូវកំណត់ដោយច្បាស់លាស់ អំពីកាតព្វកិច្ចរវាងភាគីពាក់ព័ន្ធ និងត្រូវបញ្ជាក់អំពីមធ្យោបាយ ដែលអនុញ្ញាតឱ្យគ្រូពេទ្យគោរពតាមបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ ។

គម្រោងកិច្ចសន្យាទាំងអស់ ត្រូវផ្ញើជូនទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ដើម្បីពិនិត្យ និងឆ្លើយតបវិញក្នុងរយៈពេលមួយខែ ។

**មាត្រា ៨០.-**

ការប្រកបមុខរបរវេជ្ជសាស្ត្រ ទោះស្ថិតក្រោមរូបភាពណាក៏ដោយ នៅក្នុងស្ថាប័នរដ្ឋ នៅក្នុងសមូហភាព ឬនៅក្នុងគ្រឹះស្ថានសាធារណៈ ត្រូវតែធ្វើឡើងក្រោមកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ លើកលែងតែក្នុងករណីដែលគ្រូពេទ្យនោះគឺជាភ្នាក់ងារស្របច្បាប់របស់រដ្ឋ របស់សមូហភាព ឬរបស់គ្រឹះស្ថានសាធារណៈដែលមិនបានគ្រោងចុះកិច្ចសន្យា ។ គ្រូពេទ្យត្រូវបញ្ជូនកិច្ចសន្យានោះទៅយុត្តាធិការមានសមត្ថកិច្ចនៃក្រុមប្រឹក្សាគណៈគ្រូពេទ្យ ។ កំណត់សម្គាល់របស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យ ត្រូវផ្ញើជូនទៅអាជ្ញាធររដ្ឋបាលសាមី និងជូនទៅគ្រូពេទ្យដែលពាក់ព័ន្ធ ។

## ផ្នែកទី ២
## ការប្រកបវិជ្ជាជីវៈឯកជន

**មាត្រា ៨១.-**

ជាគោលការណ៍ គ្រូពេទ្យម្នាក់ត្រូវមានបន្ទប់ពិគ្រោះជំងឺតែមួយកន្លែង ។

គ្រូពេទ្យអាចមានបន្ទប់ពិគ្រោះជំងឺ ជាសាខាមួយទៀតបាន កាលណាគ្រូពេទ្យនោះអាចទទួលពិគ្រោះតាមធម្មតា និង យ៉ាងទៀងទាត់នៅក្នុងបន្ទប់សាខានោះ ។ ការបង្កើត ឬការរក្សាទុកបន្ទប់ពិគ្រោះ ជាសាខាក្រោមរូបភាពណាក៏ដោយ នឹងអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាត ពីក្រុមប្រឹក្សាគណៈគ្រូពេទ្យសាមី ។

ការអនុញ្ញាតនេះធ្វើទៅបាន បើគ្រូពេទ្យម្នាក់ទៀត ដែលមានជំនាញដូចគ្នា ស្ថិតនៅឆ្ងាយ មិនអាចបំពេញសេចក្តីត្រូវការរបស់អ្នកជំងឺ ដោយធានាបាននូវភាពបន្ទាន់ គុណភាព និងនិរន្តរភាពនៃការថែទាំ ។

ការអនុញ្ញាតត្រូវផ្តល់ចំពោះអ្នកសុំ និងមិនអាចផ្ទេរឱ្យអ្នកផ្សេងឡើយ ។

ការអនុញ្ញាតមានកំណត់ត្រឹមបីឆ្នាំ និងអាចបន្តបាន លុះត្រាតែបានទទួលការអនុញ្ញាតជាថ្មី ពីក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។

ការអនុញ្ញាតអាចត្រូវដកយកវិញ នៅគ្រប់ពេលវេលា ពិសេសនៅពេលមានគ្រូពេទ្យម្នាក់ទៀត ដែលមានសមត្ថភាពដូចគ្នាមកបើកទីតាំង ដើម្បីបម្រើសេចក្តីត្រូវការរបស់អ្នកជំងឺនៅទីនោះ ។

ក្នុងករណីណាក៏ដោយ គ្រូពេទ្យម្នាក់មិនអាចមានបន្ទប់ពិគ្រោះ ជាសាខា លើសពីមួយកន្លែងទេ ។

**មាត្រា ៨២.-**

គ្រូពេទ្យ ឬនិស្សិតអន្តេវាសិកវេជ្ជសាស្ត្រ ដែលបានធ្វើការជំនួសសហភាគរៈណាមួយ អស់រយៈពេលបីខែយ៉ាងតិច មិនត្រូវបើកបន្ទប់ពិគ្រោះជំងឺ មុនរយៈពេលពីរឆ្នាំ នៅទីតាំងដែលអាចបង្កឱ្យមានការប្រកួតប្រជែងផ្ទាល់ ជាមួយគ្រូពេទ្យ

ដែលខ្លួនបានជំនួស និងជាមួយគ្រូពេទ្យដែលកំពុងរួមការងារ ជាមួយគ្រូពេទ្យដែលខ្លួនបានជំនួស លើកលែងតែមានការយល់ព្រមពីភាគីទាំងអស់ ដោយត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។

ក្នុងករណីភាគីទាំងអស់មិនឯកភាពគ្នា ការបើកទីតាំងត្រូវទទួលបានការអនុញ្ញាត ពីក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។

**មាត្រា ៨៣.-**

ការប្រើប្រាស់គ្រូពេទ្យម្នាក់ ឬនិស្សិតវេជ្ជសាស្ត្រម្នាក់ នៅក្នុងបន្ទប់ពិគ្រោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ត្រូវហាមឃាត់ ។

- ប៉ុន្តែគ្រូពេទ្យអាចហៅរកជំនួយ ក្នុងករណីមានអ្នកជំងឺច្រើនហួសហេតុ នៅក្នុងតំបន់ណាមួយជាកំណត់ ។

នៅក្នុងយថាហេតុនេះ បើអ្នកជំនួយជាគ្រូពេទ្យ ត្រូវសុំការអនុញ្ញាតពីក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។ បើអ្នកជំនួយជានិស្សិតវេជ្ជសាស្ត្រ ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរខេត្ត ក្រុងសាមី ក្នុងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ ។

បទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ មិនបានហាមឃាត់ការបំពេញកម្មសិក្សាបណ្តុះបណ្តាលសាកលវិទ្យាល័យ របស់និស្សិតវេជ្ជសាស្ត្រនៅជាមួយគ្រូពេទ្យប្រតិបត្តិ ដែលស្ថិតនៅក្នុងល័ក្ខខ័ណ្ឌនៃច្បាប់ឡើយ ។

**មាត្រា ៨៤.-**

តាមបដិប្បញ្ញត្តិក្នុងកថាខណ្ឌទី១ នៃមាត្រា៨៣ នៃអនុក្រឹត្យនេះ គ្រូពេទ្យអាចត្រូវបានជំនួយក្នុងការងាររបស់ខ្លួនដោយគ្រូពេទ្យម្នាក់ទៀត នៅក្នុងកាលៈទេសៈពិសេស ដូចជាក្នុងពេលមានការរាតត្បាតនៃជំងឺឆ្លង ឬសុខភាពរបស់គ្រូពេទ្យនោះតម្រូវឱ្យធ្វើ ។ ការអនុញ្ញាតត្រូវបានទទួលការយល់ព្រមពិសេស ពីក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង សម្រាប់រយៈពេលបីខែ និងអាចបន្តជាយថាហេតុ។

**មាត្រា ៨៥.-**

គ្រូពេទ្យមិនត្រូវអនុញ្ញាតឱ្យសហភាតរៈណាម្នាក់កាន់កាប់បន្ទប់ពិគ្រោះជំងឺរបស់ខ្លួនឡើយ ។

ប៉ុន្តែក្រុមប្រឹក្សាគណៈគ្រូពេទ្យអាចអនុញ្ញាតសម្រាប់រយៈពេលបីខែ ឬបន្តបីខែម្តងទៀតជាយថាហេតុ ឱ្យគ្រូពេទ្យម្នាក់កាន់កាប់បន្ទប់ពិគ្រោះជំងឺ របស់សហភាតរៈដែលបានទទួលមរណភាព ។

**មាត្រា ៨៦.-**

- គ្រូពេទ្យមិនត្រូវតាំងទីពិគ្រោះជំងឺ នៅក្នុងអាគារមួយដែលមានសហភាតរៈម្នាក់កំពុងប្រកបវិជ្ជាជីវៈជំនាញដូចគ្នានោះឡើយ បើពុំមានការយល់ព្រមពីសហភាតរៈនេះ ឬពុំបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង។

**មាត្រា ៨៧.-**

សមាគម ឬក្រុមហ៊ុនរវាងគ្រូពេទ្យដើម្បីប្រកបមុខរបរវិជ្ជាជីវៈ ត្រូវតែប្រព្រឹត្តទៅក្រោមកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរដែលគោរពឯករាជ្យភាពវិជ្ជាជីវៈរបស់គ្រូពេទ្យម្នាក់ៗ ។

កិច្ចសន្យា និងលិខិតពាក់ព័ន្ធ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ដើម្បីពិនិត្យភាពសមស្របជាមួយ

និងបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ព្រមជាមួយ ខ សំខាន់ៗជាសារវន្ត នៃកិច្ចសន្យាគំរូ ដែលបានរៀបចំឡើងដោយគណៈគ្រូពេទ្យជាតិ បើសិនជាមាន ។

**មាត្រា ៨៨.-**

គ្រូពេទ្យមិនអាចទទួលកិច្ចសន្យាដែលមាន ខ ណាមួយ ចំណុះការបង្កើនផលប្រយោជន៍ របស់សហគ្រាសទៅនឹងការផ្តល់រង្វាន់ ឬ រយៈពេលនៃកិច្ចសន្យា ហើយដែលអាចបង្កផលវិបាកប៉ះពាល់ ដល់ឯករាជ្យភាពក្នុងការសម្រេច ឬដល់គុណភាព នៃការថែទាំរបស់គ្រូពេទ្យ ។

**មាត្រា ៨៩.-**

នៅក្នុងអាគារពិគ្រោះជំងឺ ដែលមានគ្រូពេទ្យច្រើននាក់ធ្វើការរួមគ្នា ទោះស្ថិតនៅក្រោមលក្ខន្តិកៈ គតិយុត្តណាក៏ដោយ ការអនុវត្តការងារវេជ្ជសាស្ត្រ ត្រូវស្ថិតនៅជាការងាររបស់បុគ្គលផ្ទាល់ ។ គ្រូពេទ្យម្នាក់ៗត្រូវរក្សាឯករាជ្យភាពវិជ្ជាជីវៈ ។

សិទ្ធិជ្រើសរើសគ្រូពេទ្យរបស់អ្នកជំងឺ ត្រូវតែបានគោរព ។

គ្រូពេទ្យម្នាក់ៗត្រូវធ្វើការពិគ្រោះ តែនៅក្នុងបន្ទប់របស់ខ្លួនផ្ទាល់ លើកលែងតែមានភាពបន្ទាន់ ឬក្នុងពេលយាមកាម ។

គ្រូពេទ្យម្នាក់ៗអាចប្រើក្រដាសស្នាម ដែលមានសញ្ញារបស់សមាគម ឬក្រុមហ៊ុនដែលគ្រូពេទ្យនោះជាសមាជិក ។ ហត្ថលេខារបស់គ្រូពេទ្យត្រូវអមផងដោយឈ្មោះ និងមានអាសយដ្ឋានភ្ជាប់ជាមួយ ។

**មាត្រា ៩០.-**

នៅក្នុងសមាគមគ្រូពេទ្យ និងនៅក្នុងបន្ទប់ពិគ្រោះជំងឺរួមគ្នា ការបែងចែកចំនួនប្រាក់រកបានរវាងគ្រូពេទ្យ ត្រូវហាមឃាត់ លើកលែងតែក្នុងករណីដែលគ្រូពេទ្យនៅក្នុងសមាគម ប្រកបមុខរបរខាងវេជ្ជសាស្ត្រទូទៅដូចគ្នា ឬជាគ្រូពេទ្យឯកទេសក្នុងមុខវិជ្ជាណាមួយដូចគ្នា ។

## ផ្នែកទី ៣
## ការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រមានប្រាក់បៀវត្ស

**មាត្រា ៩១.-**

អំពើដែលគ្រូពេទ្យម្នាក់បានយល់ព្រមប្រកបវិជ្ជាជីវៈ ក្រោមកិច្ចសន្យា ឬលក្ខន្តិកៈជាមួយរដ្ឋ ជាមួយសមូហភាព ឬ ជាមួយអង្គការសាធារណៈ ឬឯកជន មិនបណ្តាលឱ្យបាត់បង់ករណីយកិច្ច និងកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ និងឯករាជ្យភាពក្នុងការសម្រេចចិត្តរបស់គ្រូពេទ្យឡើយ ។

ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ គ្រូពេទ្យមិនអាចទទួលការដាក់កម្រិតទៅលើឯករាជ្យភាព ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ ពីសំណាក់សហគ្រាស ឬពីអង្គការដែលជានិយោជក របស់គ្រូពេទ្យនោះបានឡើយ ។ គ្រូពេទ្យត្រូវបំពេញការងារ ដោយឱ្យអាទិភាពទៅលើផលប្រយោជន៍សុខាភិបាលសាធារណៈ ទៅលើផលប្រយោជន៍ និងសុវត្ថិភាព

របស់អ្នកធ្វើការនៅក្នុងផ្ទៃសហគ្រាស ឬ សមូហភាពដែលគ្រូពេទ្យនោះប្រកបមុខរបរ ។

**មាត្រា ៩២.-**

ដោយមិនគិតពីបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានសុខាភិបាល សំណុំលិខិតវេជ្ជសាស្ត្រផ្សេងៗត្រូវរក្សាទុក ក្រោមការទទួលខុសត្រូវ របស់គ្រូពេទ្យដែលបានរៀបរៀង ។

**មាត្រា ៩៣.-**

គ្រូពេទ្យមានប្រាក់បៀវត្ស ក្នុងករណីណាក៏ដោយ មិនអាចទទួលប្រាក់រង្វាន់ ដោយសំអាងលើបទដ្ឋានផលិត លើបទដ្ឋានទិន្នផល ឬ កិច្ចចាត់ចែងផ្សេងទៀត ដែលអាចបណ្តាលឱ្យមានការកំណត់ ឬបោះបង់ឯករាជ្យភាព ឬឱ្យប៉ះពាល់ដល់គុណភាពនៃការថែទាំ ។

**មាត្រា ៩៤.-**

គ្រូពេទ្យដែលប្រកបមុខរបរ នៅក្នុងសេវាឯកជន ឬសាធារណៈ ក្នុងការថែទាំ ឬការពារជំងឺ មិនអាចប្រើប្រាស់មុខងារនេះ ដើម្បីបង្កើនអតិថិជនរបស់ខ្លួនឡើយ ។

**មាត្រា ៩៥.-**

លើកលែងតែក្នុងករណីបន្ទាន់ ឬកំណត់ដោយច្បាប់ គ្រូពេទ្យដែលទទួលខុសត្រូវសេវាវេជ្ជសាស្ត្របង្ការ ចំពោះសមូហភាពណាមួយ ពុំមានសិទ្ធិធ្វើការព្យាបាលឱ្យសមូហភាពនោះឡើយ ។

គ្រូពេទ្យនេះត្រូវបញ្ជូនអ្នកជំងឺទៅគ្រូពេទ្យព្យាបាល ឬគ្រូពេទ្យណាមួយផ្សេងទៀត ដែលចាត់តាំងឡើងដោយសមូហភាពនោះ ។

## ផ្នែកទី ៤
## ការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រត្រួតពិនិត្យ

**មាត្រា ៩៦.-**

គ្រូពេទ្យទទួលបន្ទុកវេជ្ជសាស្ត្រត្រួតពិនិត្យ មិនអាចធ្វើជាគ្រូពេទ្យបង្ការជំងឺ ឬជាគ្រូពេទ្យព្យាបាលអ្នកជំងឺ ដែលគ្រូពេទ្យនោះត្រួតពិនិត្យ លើកលែងតែក្នុងស្ថានភាពបន្ទាន់ ។

ការហាមប្រាមនេះធ្វើឡើងចំពោះសមាជិក នៃគ្រួសារអ្នកជំងឺ ដែលរស់នៅជាមួយគ្នា និងចំពោះសមាជិកនៃសមូហភាព បើសិនជាគ្រូពេទ្យនោះធ្វើការនៅក្នុងសមូហភាព ។

**មាត្រា ៩៧.-**

នៅក្នុងតំណែងនៃបេសកកម្ម គ្រូពេទ្យត្រួតពិនិត្យត្រូវហាមបដិសេធ បើសិនជាយល់ឃើញថា សំណួរដែលបានចោទសួរមិនស្ថិតនៅក្នុងបច្ចេកទេសវេជ្ជសាស្ត្រ មិនស្ថិតនៅក្នុងសមត្ថភាព នៅក្នុងលទ្ធភាពរបស់គ្រូពេទ្យ ឬដែលអាចជំរុញគ្រូពេទ្យនោះ ឱ្យប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិផ្សេងៗនៃអនុក្រឹត្យនេះ ។

**មាត្រា ៩៨.-**

គ្រូពេទ្យត្រួតពិនិត្យ ត្រូវបញ្ជាក់ប្រាប់អ្នកដែលត្រូវត្រួតពិនិត្យ អំពីបេសកកម្ម និងក្របខណ្ឌច្បាប់ ដែលបេសកកម្មនេះត្រូវអនុវត្ត និងកំណត់ព្រំដែនរបស់ខ្លួន ។

គ្រូពេទ្យត្រួតពិនិត្យ ត្រូវប្រុងប្រយ័ត្នក្នុងការនិយាយស្ដីរបស់ខ្លួន និងមិនត្រូវបញ្ចេញការសម្ងាត់ ឬ មិនត្រូវធ្វើអត្ថាធិប្បាយអំពីបេសកកម្ម ។

គ្រូពេទ្យត្រួតពិនិត្យមិនត្រូវលំអៀងក្នុងការសន្និដ្ឋាន ។

**មាត្រា ៩៩.-**

- គ្រូពេទ្យត្រួតពិនិត្យ មិនត្រូវជ្រៀតជ្រែកក្នុងការព្យាបាល ឬកែប្រែការព្យាបាលឡើយ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ កំណត់ដោយច្បាប់ ។ ក្នុងពេលកំពុងពិនិត្យ បើគ្រូពេទ្យត្រួតពិនិត្យ មិនយល់ស្របនឹងគ្រូពេទ្យព្យាបាល ទៅលើការធ្វើរោគវិនិច្ឆ័យ ទៅលើបុរេនិមិត្ត ឬបានយល់ឃើញថាគ្រូពេទ្យព្យាបាលមិនបានគិតដល់កត្តាសំខាន់ និងមានប្រយោជន៍ក្នុងការព្យាបាល គ្រូពេទ្យត្រួតពិនិត្យ ត្រូវជម្រាបគ្រូពេទ្យព្យាបាលដោយផ្ទាល់ ។ ក្នុងករណីជួបការលំបាកចំពោះរឿងនេះ គ្រូពេទ្យត្រួតពិនិត្យ អាចស្នើយោបល់ទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។

**មាត្រា ១០០.-**

គ្រូពេទ្យត្រួតពិនិត្យ ត្រូវរក្សាការសម្ងាត់ចំពោះរដ្ឋអំណាច ឬអង្គភាពដែលបានអញ្ជើញឱ្យមកធ្វើការងារនេះ ។ គ្រូពេទ្យត្រួតពិនិត្យ អាចផ្ដល់ដល់រដ្ឋអំណាច ឬអង្គភាពទាំងនោះតែសេចក្ដីសន្និដ្ឋានលើវិស័យរដ្ឋបាល ដោយមិនចាំបាច់បញ្ជាក់អំពីមូលហេតុផ្នែកវេជ្ជសាស្ត្រទេ ។

ព័ត៌មានវេជ្ជសាស្ត្រដែលមានឈ្មោះ ឬដែលអាចឱ្យស្គាល់ឈ្មោះ នៅក្នុងសំណុំឯកសារ ដែលរៀបរៀងឡើងដោយគ្រូពេទ្យនោះ មិនអាចផ្ដល់ទៅឱ្យអ្នកក្រៅសេវាវេជ្ជសាស្ត្រ រដ្ឋអំណាច ឬអង្គភាពណាមួយឡើយ ។

## ផ្នែកទី ៥
## ការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រកោសល្យវិច័យ

**មាត្រា ១០១.-**

គ្រូពេទ្យម្នាក់មិនអាចធ្វើជាគ្រូពេទ្យកោសល្យវិច័យផង និងជាគ្រូពេទ្យព្យាបាលផង ចំពោះអ្នកជំងឺដែលបានឡើយ ។ គ្រូពេទ្យមិនត្រូវទទួលបេសកកម្មកោសល្យវិច័យ ដែលជាប់ទាក់ទងនឹងផលប្រយោជន៍របស់ខ្លួនផ្ទាល់ របស់អ្នកជំងឺណាម្នាក់ របស់សាច់ញាតិ របស់មិត្តភ័ក្ត ឬរបស់សមូហភាព ដែលតែងត្រូវការសេវារបស់គ្រូពេទ្យនោះ ។

**មាត្រា ១០២.-**

នៅក្នុងតំណែងនៃបេសកកម្ម គ្រូពេទ្យកោសល្យវិច័យត្រូវហ៊ានបដិសេធ បើសិនជាយល់ឃើញថា សំនួរដែលចោទសួរ មិនស្ថិតនៅក្នុងបច្ចេកទេសវេជ្ជសាស្ត្រ មិនស្ថិតនៅក្នុងសមត្ថភាព ឬនៅក្នុងលទ្ធភាពរបស់គ្រូពេទ្យ ឬដើម្បីជំរុញគ្រូពេទ្យនោះឱ្យប្រព្រឹត្តផ្ទុយ នឹងបទប្បញ្ញត្តិផ្សេងៗនៃអនុក្រឹត្យនេះ ។

**មាត្រា ១០៣.-**

គ្រូពេទ្យកោសល្យវិច័យ មុននឹងចាប់អនុវត្តកោសល្យវិច័យ ត្រូវប្រាប់អ្នកដែលត្រូវពិនិត្យ អំពីបេសកកម្ម និងក្របខ័ណ្ឌច្បាប់ដែលគ្រូពេទ្យត្រូវមានមតិ ។

**មាត្រា ១០៤.-**

ក្នុងការសរសេររបាយការណ៍ គ្រូពេទ្យកោសល្យវិច័យ ត្រូវបង្ហាញតែវត្ថុធាតុ ដែលអាចផ្តល់ចម្លើយ ចំពោះសំនួរដែលបានលើកឡើង ។ ក្រៅពីនេះគ្រូពេទ្យកោសល្យវិច័យ មិនត្រូវបង្ហាញអ្វីទាំងអស់ ដែលគ្រូពេទ្យបានដឹងនៅក្នុងពេលធ្វើកោសល្យវិច័យនោះ ។

- គ្រូពេទ្យកោសល្យវិច័យត្រូវបញ្ជាក់ថា បានបំពេញបេសកកម្មដោយខ្លួនឯងផ្ទាល់ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១០៥.-**

គ្រូពេទ្យទាំងអស់ នៅពេលសុំចុះឈ្មោះនៅក្នុងបញ្ជី ត្រូវបញ្ជាក់នៅចំពោះមុខក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ថា : បានយល់ដឹងពីអនុក្រឹត្យស្តីពីក្រមសីលធម៌គ្រូពេទ្យនេះរួចហើយ និងសន្យាក្រោមសម្បថ និងជាលាយលក្ខណ៍អក្សរថា : គោរពតាមក្រមសីលធម៌នេះ ។

**មាត្រា ១០៦.-**

សេចក្តីបញ្ជាក់មិនត្រឹមត្រូវ ឬមិនពេញលេញដោយចេតនា ធ្វើឡើងជូនក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ដោយគ្រូពេទ្យម្នាក់អាចនាំឱ្យមានការចោទប្រកាន់ខាងវិន័យ ។

**មាត្រា ១០៧.-**

គ្រូពេទ្យដែលកែប្រែល័ក្ខខ័ណ្ឌនៃការប្រកបមុខរបរ ឬបោះបង់ការប្រកបមុខរបរ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង ។ ក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុងទទួលដឹងឮការប្រែប្រួលនេះ និងជូនដំណឹងទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ។

**មាត្រា ១០៨.-**

សេចក្តីសម្រេចទាំងឡាយរបស់គណៈគ្រូពេទ្យគ្រប់ជាន់ថ្នាក់ ក្នុងការអនុវត្តតាមអនុក្រឹត្យនេះ ត្រូវតែមានមូលហេតុច្បាស់លាស់ ។

**មាត្រា ១០៩.-**

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត ក្រុង អាចត្រូវធ្វើឡើងវិញ ឬត្រូវចាត់ទុកជាមោឃៈ ដោយក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ដោយបញ្ញត្តិ ឬតាមសំណូមពរពីសាមីជនពាក់ព័ន្ធ ។ សំណូមពរនេះត្រូវធ្វើឡើងក្នុងរយៈពេលពីរខែ ក្រោយបានទទួលសេចក្ដីសម្រេច ។

**មាត្រា ១១០.-**

អនុលោមតាមមាត្រា២៦នៃព្រះរាជក្រឹត្យលេខនស/រកត/០២០០/០៣៩ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ស្ដីពីការបង្កើតគណៈគ្រូពេទ្យមួយ ដើម្បីប្រមូលផ្ដុំគ្រូពេទ្យទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាគណៈគ្រូពេទ្យគ្រប់ជាន់ថ្នាក់មានកាតព្វកិច្ច ឃ្លាំមើលការគោរពប្រតិបត្តិតាមបទប្បញ្ញត្តិទាំងនេះ ។ បណ្ដាបទល្មើសចំពោះបទប្បញ្ញត្តិទាំងនេះ នឹងត្រូវទទួលទោសវិន័យ អំពីក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ ដោយមានការចូលរួមពីផ្នែកវិន័យ នៃក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ។ ក្នុងករណីនេះ ប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ ជាអ្នកអនុវត្តសេចក្ដីសំរេច ។

**មាត្រា ១១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈនិងយុវៈនីតិសម្បទា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៥៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការលុបប្រកាសផ្ទេរ និង តែងតាំងមន្ត្រីរាជការ

~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញសារាចរណែនាំលេខ ១០ សរ.ណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការស៊ីវិល

## សំរេច

**មាត្រា ១ៈ** ត្រូវបានលុបប្រកាសលេខ ៣៧៤ ប្រក.សក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីការអនុញ្ញាតអោយលោក **មាន ចន្ទ័ធូ** វិលត្រឡប់ទៅបំរើការងារនៅអង្គភាពដើមវិញ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ដោយទុកជាមោឃៈ ។

**មាត្រា ២ៈ** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ
~~~~~~~

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូន Major **Michael J . Dove** US Army Pacific Contracting Officer ដែលបានចូលរួមសហការ ជួយកសាងស្ពានបេតុងមួយកន្លែង នៅឃុំចំណោម ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលជាអំណោយមនុស្សធម៌របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង និង ពលទាហាន តំបន់ប្រតិបត្តិការសឹកប៉ៃលិន និងកងការពារព្រំដែន លេខ ៥០៤ យោធភូមិភាគទី៥ នៃបញ្ជាការដ្ឋានកងទ័ពជើងគោក ចំនួន ៣៧ រូបដែលមានស្នាដៃល្អ ក្នុងការបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

**ក.<u>មេដាយមាសការងារ</u> :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **យឹម សេត** | អត្តលេខ ០០៣៩៤៣ | តំបន់ប្រតិបត្តិការសឹកក្រុងប៉ៃលិន |
| ២-វរសេនីយ៍ទោ | **ឈិន រាមា** | អត្តលេខ ០០០៦៥៨ | តំបន់ប្រតិបត្តិការសឹកក្រុងប៉ៃលិន |
| ៣-វរសេនីយ៍ទោ | **ព្រហ្ម ផាត់** | អត្តលេខ ០០៣៨៦៣ | មេបញ្ជាការ កងការពារព្រំដែនគោក លេខ៥០៤ |
| ៤-វរសេនីយ៍ទោ | **ជឹម ចំណាន** | អត្តលេខ ០០៤៦២៥ | នាយទាហាន យោធភូមិភាគទី៥ |
| ៥-វរសេនីយ៍ត្រី | **សុខ គឹមសាន្ត** | អត្តលេខ ០០៣៥០៨ | មេបញ្ជាការរងកងការពារព្រំដែនគោក លេខ៥០៤ |
| ៦-វរសេនីយ៍ត្រី | **អ៊ូ គឹមឡុន** | អត្តលេខ ០០៥២៤៥ | មេបញ្ជាការរងកងការពារព្រំដែនគោក លេខ៥០៤ |

៧-វរសេនីយ៍ត្រី **វណ្ណា ដារ៉ា** អត្តលេខ ០០៩១០៧ មេបញ្ជាការរងកងការពារព្រំដែនគោក លេខ៥០៤

៨-វរសេនីយ៍ត្រី **សាន្ត វាសនា** អត្តលេខ ០១១៩៩២ មេបញ្ជាការរងកងការពារព្រំដែនគោក លេខ៥០៤

៩-វរសេនីយ៍ត្រី **ម៉ុន ម៉ែន** អត្តលេខ ០០២៣៦៤ នាយសេនាធិការកងការពារព្រំដែនគោកលេខ៥០៤

**ខ.<u>មេដាយប្រាក់ការងារ</u> :**

១-វរសេនីយ៍ទោ **ដួង ដារា** អត្តលេខ ០០៣៩៥៧ តំបន់ប្រតិបត្តិការសឹកក្រុងប៉ៃលិន

២-អនុសេនីយ៍ឯក **ប៊ុក សំហួន** អត្តលេខ ០១១៩៤៦ តំបន់ប្រតិបត្តិការសឹកក្រុងប៉ៃលិន

៣-អនុសេនីយ៍ឯក **អ៊ិន សារឿន** អត្តលេខ ០២១៦៦២ នាយសេនាធិការរងកងការពារព្រំដែនគោក លេខ៥០៤

៤-អនុសេនីយ៍ឯក **សុខ គេង** អត្តលេខ ០២២០៨៤ នាយសេនាធិការរងកងការពារព្រំដែនគោក លេខ៥០៤

៥-អនុសេនីយ៍ឯក **សំ សុធី** អត្តលេខ ០១៩២៧១ មេបញ្ជាការ កងល្បាតទី ១

៦-អនុសេនីយ៍ឯក **ខ្មៅ សុវណ្ណ** អត្តលេខ ០២១៩៩៥ មេបញ្ជាការ កងល្បាតទី ២

៧-អនុសេនីយ៍ឯក **យ៉េយ ស៊ីដូ** អត្តលេខ ០២៣២៥០ មេបញ្ជាការ កងល្បាតទី ៥

៨-អនុសេនីយ៍ឯក **សយ ឈឿន** អត្តលេខ ០៣០៨៩៤ មេបញ្ជាការ កងល្បាតទី ៦

៩-អនុសេនីយ៍ឯក **វ៉េត វ៉ាត់** អត្តលេខ ០១៦៤១៣ មេបញ្ជាការ កងល្បាតទី ៤

១០-អនុសេនីយ៍ទោ **ផន សុផល** អត្តលេខ ០៥២៥១១ ជំនួយការ បុគ្គលិក

១១-អនុសេនីយ៍ទោ **ស៊ុន សុភឿន** អត្តលេខ ០២១៦៥៣ ជំនួយការ ចលនូបត្ថម្ភ

១២-អនុសេនីយ៍ទោ **នោម គីមធី** អត្តលេខ ០៣៧៥៩៨ ជំនួយការ ហិរញ្ញវត្ថុ

១៣-នាយចំណង់ **នង់ រ៉ែន** អត្តលេខ ០៤៤៣៥៨ ជំនួយការ ប្រតិបត្តិការ

១៤-ព្រឹន្ទបាលឯក **សុខ សុធា** អត្តលេខ ០៨១៩១៣ ជំនួយការ បុគ្គលិក

**គ.<u>មេដាយសំរឹទ្ធការងារ</u> :**

១-អនុសេនីយ៍ទោ **ប្រាក់ ស៊ីថា** អត្តលេខ ០២១៩៥៤ តំបន់ប្រតិបត្តិការសឹកក្រុងប៉ៃលិន

២-អនុសេនីយ៍ទោ **ម៉ង់ ឈ៊ាវ** អត្តលេខ ០៣៣០១៩ មេបញ្ជាការរង កងល្បាតទី ១

៣-អនុសេនីយ៍ទោ **សំ សុង** អត្តលេខ ០២១៦២៦ មេបញ្ជាការរង កងល្បាតទី ២

៤-អនុសេនីយ៍ទោ **ម៉ៅ សុខុម** អត្តលេខ ០៣០៨៨៥ មេបញ្ជាការរង កងល្បាតទី ៦

៥-អនុសេនីយ៍ទោ **យ៉ី ជឿន** អត្តលេខ ០៣០៩០៨ មេបញ្ជាការរង កងល្បាតទី ៦

៦-អនុសេនីយ៍ទោ **បឿវ មាន** អត្តលេខ ០៣០៨៨៨ មេបញ្ជាការរង កងល្បាតទី ៤

៧-អនុសេនីយ៍ទោ **គង់ ធី** អត្តលេខ ០១២៥៩៩ ជំនួយការ ហ្វឹកហ្វឺន

៨-នាយចំណង់ **យឹម ថន** អត្តលេខ ០៤៤៣៥៩ ជំនួយការគោលនយោបាយ តំបន់ប្រតិបត្តិការ សឹកក្រុងប៉ៃលិន

| | | | | |
|---|---|---|---|---|
| ៩-នាយចំណង់ | **នឹម នួន** | អត្តលេខ | ០៤២៦៥៤ | បុគ្គលិកប្រតិបត្តិការ |
| ១០-ព្រិន្ទបាលទោ | **មាស សុភាព** | អត្តលេខ | ០៥៥៥០៣ | បុគ្គលិកប្រតិបត្តិការ |
| ១១-ពលបាលទោ | **ឆាំ ស្រិត** | អត្តលេខ | ១៩១០១៥ | បុគ្គលិកប្រតិបត្តិការ |
| ១២-ពលបាលទោ | **ឈិន ណុប** | អត្តលេខ | ០១៨៩២៩ | មេបញ្ជាការរង កងអនុសេនាតូចគាំទ្រ |
| ១៣-ពលបាលទោ | **កែវ សំអាត** | អត្តលេខ | ០៨១៩៣៩ | បញ្ជូនសារ |
| ១៤-ពលឯក | **នាង សំនិត** | អត្តលេខ | ១៣០៦៩០ | មេបញ្ជាការ កងអនុសេនាតូចស៊ើបការ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៦ អនក្រ-បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគថវិកា ជួយឧបត្ថម្ភដល់ការកសាងអង្គភាពកងការពារព្រំដែនលេខ៩០៤ យោធភូមិភាគទី៥ ដូចមានរាយនាមខាងក្រោម :

**<u>ក_មេដាយមាសស្ថាបនាជាតិ</u> :**

១-ឯកឧត្តម **អ៊ី ឈាន** អភិបាលក្រុងប៉ៃលិន ថវិកា ចំនួន ១០.០០០ USD

២-វរសេនីយ៍ទោ **ព្រហ្ម ផាត់** មេបញ្ជាការកងការពារព្រំដែនគោក ថវិកា ចំនួន ១០.០០០ USD

**ខ. មេដាយសេរីវឌ្ឍនាបនាជាតិ :**

- ឧត្តមសេនីយ៍ត្រី **ឈុន ញឹម** មេបញ្ជាការរង យោធភូមិភាគទី៥ ថវិកា ចំនួន ១.០០០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ...៦៤៥.៧៣...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម Hans-Peter Erismann ឯកអគ្គរដ្ឋទូត វិសាមញ្ញ និង ពេញសមត្ថភាព នៃសហព័ន្ធស្វីស ប្រចាំព្រះរាជាណាចក្រកម្ពុជា និវេសនដ្ឋាន នៅក្រុងបាងកក ដែលបានផ្តល់ អំណោយជាថវិកា ចំនួន ១១.៤២៨ ដុល្លារអាមេរិក ដល់នាយកដ្ឋានតំកល់ឯកសារជាតិ នៃ ទីស្តីការគណៈ រដ្ឋមន្ត្រី សំរាប់ជួសជុលអគារ បណ្ណសារដ្ឋានជាតិ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ចំនួន ០៤គ្រឿង ជូនសប្បុរសជនជប៉ុន និង ខ្មែរ ដែលបានឧបត្ថម្ភថវិកា សំរាប់ជួយកសាងអគារសិក្សា និង ឧបត្ថម្ភ សម្ភារៈសិក្សា ដូចមាននាមខាងក្រោម :-

**ក-ជូនមេដាយមាសស្ថាបនាជាតិ** ចំនួន ០៣គ្រឿង ចំពោះលោកស្រី **OSANAI MIEKO** ប្រធានអង្គការ **JHP** ជប៉ុន ដែលបានផ្តល់ថវិកា សំរាប់ជួយសាងសង់អគារសិក្សា ០៣កន្លែង ដូចខាងក្រោម :-

១-អគារសិក្សា ០១ខ្នង នៅសាលាបឋមសិក្សាក្រាំងស្គរ ឃុំក្រាំងតាយ៉ង ស្រុកពាមជរ ខេត្តព្រៃវែង ចំណាយអស់ថវិកា ចំនួន ២៧.០០០ USD ។

២-អគារសិក្សា០១ខ្នង នៅសាលាបឋមសិក្សាបន្ទេច ឃុំពាមមានជ័យ ស្រុកពាមរក៍ ខេត្តព្រៃវែង ចំណាយអស់ថវិកា ចំនួន ២៧.០០០ USD ។

៣-អគារសិក្សា០១ខ្នង និងបង្គន់អនាម័យ ០១ខ្នង នៅសាលាបឋមសិក្សាសំបួរ ឃុំច្បារមន ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកា ចំនួន ២៩.៥២០ USD ។

**ខ-ជូនមេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ចំពោះលោក **គីម ឡុល** ប្រធានសាខាគយ និង រដ្ឋាករ ខេត្តតាកែវ ដែលបានជួយកសាងអគារសិក្សា ០១ខ្នង នៅសាលាបឋមសិក្សាភ្នំតូច ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកា ចំនួន ១៨.៥០០ USD ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៨ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច ✓

-ឯកសារ-កាលប្បវត្តិ

122

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំរេច

**មាត្រា ១៖** តែងតាំងលោក **ហ៊ុន ស៊ុធី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា ២៖** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧២០ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូពាមជាំង

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូពាមជាំង
- បានឃើញអនុក្រឹត្យលេខ ៤៦៧ អនក្រ.តត ចុះថ្ងៃទី ១៦ ខែសីហា. ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូពាមជាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំ រេ ច

**មាត្រា១ :** តែងតាំងលោក **មេវ ម៉ុនថន** អនុប្រធានការិយាល័យសហគ្រាសសាធារណៈ នៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូពាមជាំង ជំនួសលោក **អ៊ូន ម៉ុនហាក់** ដែលបានផ្ទេរទៅកាន់ភារកិច្ចថ្មី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី... ខែសីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ចំការកៅស៊ូពាមជាំង
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៦១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រី **ដូមីនិក ម៉ាក់អាដាម** (**Ms. Dominique McAdams**) តំណាងអង្គការ UNDP ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាន គុណបំណាច់ និង ស្នាដៃល្អ ក្នុងការជួយស្តារ និង អភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា លើគ្រប់វិស័យ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែល ត្រូវជូន គ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៩៧៦/៧...អនក្រ-ធក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន ASSOCIATION OF FOREST REHABILITATION នៅប្រទេសជប៉ុន ដែលបានផ្តល់អំណោយជាថវិកាចំនួន ១៦.៧០០ ដុល្លារ សំរាប់ ជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៣ បន្ទប់ បំពាក់សម្ភារីមគ្រប់គ្រាន់ បង្គន់អនាម័យ ០៤ បន្ទប់ និង អណ្តូងទឹកមួយ ជូនសាលាបឋមសិក្សាប្រាង្គសុវណ្ណ ឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ១៦ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារ ជួយកសាង និង អភិវឌ្ឍន៍ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម÷

**ក-មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-ឯកឧត្តម | **តែ គុយសៀង** | អគ្គនាយក ទទួលបន្ទុករដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល |
| ២-លោក | **ឆេស សុខម៉េង** | អគ្គនាយករង ទទួលបន្ទុករដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ |
| ៣-លោក | **មាស សារុន** | អគ្គនាយករង ទទួលបន្ទុករដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ |
| ៤-លោក | **ពេជ្រ កែវ** | អគ្គនាយករង ទទួលបន្ទុកបច្ចេកទេស នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ |

៥- លោក ម៉ែន សេរីវុឌ្ឍ ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវតុល្យភាពការងារ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

៦- លោក ស្រី សួន ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

៧- លោកស្រី នេត ភូម៉ារី អនុប្រធាននាយកដ្ឋានសំភារៈនិងបរិក្ខារ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

៨- លោក ចំរើន វណ្ណថា អធិការនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

៩- លោក ហាក់ សុផាន់ណា សកលវិទ្យាធិការរង វិទ្យាសាស្ត្រ នៃក្រសួងសុខាភិបាល

១០- លោក ភា ស៊ុនបូណាត ព្រឹទ្ធបុរសមហាវិទ្យាល័យ វេជ្ជសាស្ត្រ នៃក្រសួងសុខាភិបាល

១១- លោក សៀង ថារិទ្ធ ព្រឹទ្ធបុរសមហាវិទ្យាល័យ វេជ្ជសាស្ត្រ នៃក្រសួងសុខាភិបាល

ខ. <u>មេដាយប្រាក់ការងារ</u> :

១- លោកវរៈសេនីយ៍ឯក ទេង សុធី អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃក្រសួងមហាផ្ទៃ

២- លោក គង់ ផាណាហា ប្រធានការិយាល័យហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល

៣- លោក អ៊ឹម ពុទ្ធារី ប្រធានការិយាល័យរដ្ឋបាល នៃក្រសួងសុខាភិបាល

៤- លោក ស៊ឹម សុខ អនុប្រធានការិយាល័យ រដ្ឋបាល នៃក្រសួងសុខាភិបាល

៥- លោកស្រី អ៊ុក សារ៉ែ អនុប្រធានការិយាល័យហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៧ ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦២. សសរ

## សេចក្តីសំរេច

**ស្តីពី**

**ការបង្កើតគណៈកម្មការដេញថ្លៃគំរោងផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតទៅត្រពាំងរពៅ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការដេញថ្លៃគំរោងផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតទៅត្រពាំងរពៅ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម | **វង្ស វិសុទ្ធ** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម | **ឈិន គង់ហ៊ាន** | អគ្គនាយកនៃនាយកដ្ឋានសាធារណៈការនិងដឹកជញ្ជូន | សមាជិក |
| ៤-លោក | **ទៅ ស៊ីមសុរិយា** | ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៥-បណ្ឌិត | **ជា វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ គ.រ.ម. | សមាជិក |
| ៦-លោក | **ម៉ៅ យុទ្ធថា** | ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី ស.ហ.វ. | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចប្រកាសដេញថ្លៃជ្រើសរើសក្រុមហ៊ុនស្ថាបនាផ្លូវជាតិលេខ ៣ ពីទីរួមខេត្តកំពតទៅត្រពាំងរពៅ ក្រោមហិរញ្ញប្បទាននៃឥណទានសម្បទានរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ។

**ប្រការ៣ :** រាល់ទំនាក់ទំនងរវាងភាគីកម្ពុជានិងភាគីកូរ៉េ ត្រូវធ្វើឡើងតាមរយៈប្រធានគណៈកម្មការ ។ រាល់បទប្បញ្ញត្តិនានា ដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ សីហា ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦០៦ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបំពេញបន្ថែមការណែនាំអនុវត្តប្រមូលពន្ធប្រថាប់ត្រា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញ ព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញ សារាចរលេខ ០៦ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រង និងការកែទម្រង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

- បានឃើញ ប្រកាសលេខ ៥០១ ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៥ ស្ដីពីការកំណត់តម្លៃគិតពន្ធប្រថាប់ត្រា
- យោងតាមការងារចំបាច់ក្នុងការប្រមូលពន្ធប្រថាប់ត្រា ។

**សំរេច**

**ប្រការ១** : ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ ឬមធ្យោបាយដឹកជញ្ជូន ដោយអនុវត្តសាលក្រមរបស់តុលាការដែលបានសំរេចរឹបអូសអចលនទ្រព្យ ដីដែលគ្មានសំណង់ ឬមធ្យោបាយដឹកជញ្ជូន របស់កូនបំណុលសំរាប់ធ្វើការទូទាត់សងបំណុល គឺមានលក្ខណៈដូចគ្នានិងការទិញលក់ដែរ ម្ចាស់បំណុលជាអ្នកបានទទួលកម្មសិទ្ធិ បានទទួលសិទ្ធិ ត្រូវបង់ពន្ធប្រថាប់ត្រា ។

**ប្រការ២** : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៣

**គាត ឈន់**

**ចម្លងជូន :**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នកណ្ដាល
- គ្រប់សាលាខេត្ត-ក្រុង

  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ